# ពិភពលោកនៃព្រះគម្ពីរលោកុប្បត្តិ

អ្នករៀបរៀង: លោកបណ្ឌិត វ៉ាយ  យ៉ុង ជុន

**ITCS**

## អារម្មណ៍កថា៖

ខ្ញុំបានអធិស្ឋានថាសូមឲ្យការកែសម្រួលជាភាសាខ្មែររបស់ព្រះគម្ពីរលោកុប្បត្តិនេះនឹងត្រូវបានបោះពុម្ពចេញមកនៅក្នុងពេលឆាប់ៗនេះសំរាប់ការងារពន្ធកិច្ច សំរាប់ការបណ្តុះនូវចំណេះដឹងពីព្រះដែលមានភាពជាអ្នកកំណែទម្រង់ និង សេចក្តីជំនឿផងដែរ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងក្រុមជំនុំខ្មែរ។ ទោះជាការកែសម្រួលជាភាសាអង់គ្លេសនិងកូរ៉េត្រូវបានបោះពុម្ពរួចក៏ដោយ ខ្ញុំនៅតែត្រូវការការកែសម្រួលជាភាសាខ្មែរសំរាប់វគ្គអប់រំតូចៗជាមួយនឹងលោកគ្រូគង្វាលផ្សេងៗនៅតាមតំបន់ផ្សេងៗ និង គ្រូៗដែលបង្រៀនគម្ពីរនិងអ្នកដឹកនាំផងដែរ។ ជាចុងក្រោយមានអ្នកបកប្រែមួយចំនួនដែលបានលះបង់ពេលវារបស់ពួកគេសំរាប់ការងារនេះ។ ខ្ញុំសូមអរគុណសំរាប់ពួកគេសំរាប់ការសហការនៅក្នុងអង្គព្រះគ្រិស្ទ៖ លោក ឈីង ធី កញ្ញា ខន ស្រីលក្ខ័ កញ្ញា ទុយ គីមអេង កញ្ញា ភេន សុធី លោក ជៀប វិជ្ជា លោក អាំ ទូច លោក យឹម កុសល កញ្ញា វិញ ស្រីរៀ និងកញ្ញា ជា សុខេន។ ជាពិសេសអ្នកជំនួយការចម្បងរបស់ខ្ញុំ កញ្ញា ខន ស្រីលក្ខ័ ដែលបានផ្តល់នូវការលះបង់ដោយមានការតាំងចិត្តនឹងតស៊ូនៅក្នុងព្រះអម្ចាស់នឹងព្រះបន្ទូលរបស់ទ្រង់ ព្រះគម្ពីររហូតការបោះពុម្ពសៀវភៅចេញមក។ ជាពិសេសនោះខ្ញុំបានមើលឃើញពីការលះបង់សំងាត់គឺជាក្រុមជំនុំដើមនៅសហរដ្ឋអាមេរិក ក្រុមជំនុំពេនីអែលប្រេសប៊ីធៀរៀន និង អ្នកឧបត្ថម្ភមួយចំនួន សេចក្តីស្រឡាញ់របស់ខ្ញុំ សិស្សនៅ ITCS របស់ខ្ញុំ ក្រុមជំនុំប្រេសប៊ីធៀរៀនកម្ពុជា និង ក្រុមជំនុំកោសិការបស់ក្រុមជំនុំពេនីអែលកម្ពុជាសំរាប់ពន្ធកិច្ចក្នុងការអប់រំដែលរឹងមាំ។ ខ្ញុំសូមអរព្រះគុណដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រិស្ទជាទីស្រឡាញ់របស់ខ្ញុំដែលបានផ្តល់នូវការបើកសំដែងដល់ខ្ញុំនៅក្នុងពេលដែលខ្ញុំមានការទុក្ខលំបាក។ ហើយព្រះទ្រង់ជ្រាបពីការស៊ូទ្រាំរបស់ប្រពន្ធរបស់ខ្ញុំ គីមប៊ីលី និង កូនស្រីគួឲ្យស្រឡាញ់ទាំងបីរបស់ខ្ញុំ អេសធើរ ស្សារុន និង មារី ដែលបានផ្គត់ផ្គង់នូវគ្រិះដ៏រឹងមាំសំរាប់ពន្ធកិច្ចនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំគួរតែរក្សាការត្រាស់ហៅរបស់ទ្រង់ដោយស្មោះត្រង់។ ខ្ញុំអធិស្ឋានថាសៀវភៅទាំងនេះនឹងអាចជាជំនួយដ៏សំខាន់សំរាប់ជួយឲ្យស្គាល់ព្រះគ្រិស្ទនឹងព្រះបន្ទូលរបស់ទ្រង់ ព្រះគម្ពីរ នៅពេលដែលនរណាម្នាក់ជួបជាមួយនឹងសៀវភៅនេះ។

១៥ វិច្ឆិកា ២០១៦

លោកបណ្ឌិត វ៉ាយ យ៉ុងជុន ពេសកជននៅកម្ពុជា

## ពិភពលោកនៃព្រះគម្ពីរលោកុប្បត្តិ

### សេចក្ដីណែនាំ:

ព្រះគម្ពីរជាការបើកសំដែងពិសេស។ ការបើកសំដែងគឺជាការបកយកនូវរាំងននគ្រប ចេញពីអ្វីមួយ។ ដូចនេះពេលដែល យើង រៀនពីព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មី យើងត្រូវតែទទួលស្គាល់ថាគ្រប់ ទាំងកណ្ឌគម្ពីរទាំងអស់ មានការពាក់ពន្ធ័គ្នាទៅវិញទៅមក ដូចជាដើមឈើមានទំនាក់ទំនងទៅនឹងឫសរបស់វាដែរ ឬ ជាទំនាក់ទំនងមួយដែលមានរបៀបរៀបរយរវាង ប្រព័ន្ធផ្នែកខាងក្នុង នឹង ប្រព័ន្ធផ្នែកខាងក្រៅ នៅខាងក្នុងផ្នែក ផ្សេងៗនៃខ្លួនមនុស្ស —ជាលំហូរ នៃជីវិត។ ការនេះរួមជាមួយ ច្បាប់របស់វិទ្យាសាស្ត្រដែរ ប៉ុន្តែលើសពីនោះទៅទៀត។ ១) យើងត្រូវតែបក ស្រាយព្រះគម្ពីរដោយប្រើព្រះគម្ពីរ។ ២) ព្រះគម្ពីរប្ញូកជាមួយពន្លឺនៃការប្រោសលោះ តាមគោលលិទ្ធិរបស់ពួកអ្នកកំនែ ទម្រង់ដែរ។ ដូចនេះនៅពេលដែលយើងសង្កេតមើលការបើកសំដែងដោយប្រុង ប្រយត្ននោះ — ការបើកសំដែងដោយ រូបភាព និង ការបើកសំដែងដោយការពន្យល់-យើងអាចមើលឃើញពន្លឺ នៃកិច្ចការរបស់ព្រះវិញ្ញាណ បរិសុទ្ធ ដោយការបក ស្រាយរូបភាពដោយការពន្យល់ ឬ ការពន្យល់ជាមួយរូបភាព។ ការបើកសំដែងនៃការប្រោសលោះត្រូវតែ បានយល់នៅ ក្នុងព្រះគ្រិស្ទ ឬ ត្រូវតែបានរួបរួម នឹង បកស្រាយ។ នៅក្នុងការបើកសំដែងទាំងនោះ កណ្ឌគម្ពីរលោកុប្បត្តិ គឺជាគន្លឹះមួយ សំរាប់បើកនូវការបើកសំដែងផ្សេងទៀត ដែរ។ ឧទាហរណ៍ ការបើកសំដែងរបស់កណ្ឌគម្ពីរលោកុប្បត្តិ ត្រូវតែបានសំរេច បំពេញដោយការបើកសំដែងរបស់កណ្ឌគម្ពីរ យ៉ូហាន។

1. លំដាប់លំដោយរបស់កណ្ឌគម្ពីរលោកុប្បត្តិ

1) ការវាយតម្លៃនៃកណ្ឌគម្ពីរលោកុប្បត្តិ

2) ព្រះអម្ចាស់ជាព្រះអាទិករ (លោកុប្បត្តិ ១:១-១៨)

3) សួនច្បារអេដែន (លោកុប្បត្តិ ២:១-៣:២៤)

4) ការថ្វាយបង្គំដ៏ពិត (លោកុប្បត្តិ ៤:១-៦)

5) ការតាំងសញ្ញែនព្រះគុណជាមួយលោកណូអេ (លោកុប្បត្តិ ៦:១-៨:២២)

6) ព្រះគុណនៃធម្មជាតិ (លោកុប្បត្តិ ៩:១-១៧)

7) ឫសដ៏រឹងមាំរបស់ដំណឹងល្អ (លោកុប្បត្តិ ១០:១-៣២)

8) ការតាំងសញ្ញារបស់លោកអ័ប្រាហាំ (លោកុប្បត្តិ ១២:១-១៩:៣២)

9) លោកអ័ប្រាហាំ (លោកុប្បត្តិ ២០:១-២៤:៦៧)

10) លោកអ៊ីសាក់ (លោកុប្បត្តិ  ២៥:១-២៦:៣៥)

11) លោកយ៉ាកុប (លោកុប្បត្តិ ២៧:១-៣៦:៤៣)

12) លោកយ៉ូសែប (លោកុប្បត្តិ ៣៧:១-៥០:២៦)

2. ឯកសារយោង

1) Yun Sun Park, *The Commentary of Genesis in the Old Testament*
2) Keil & Delitzh, *The Commentary of Genesis*
3) M. G. Kline, *Pentateuch Lecture*
4) Dillmann & Longman, *The Introduction of the O. T.*
5) E. J. Young, *The introduction of the O. T.*
6) Geerhardus Vos, *Biblical Theology*
7) Bruce Waltke, *Genesis, a Commentary*

## មេរៀនទី១ គោលគំនិតនៃរូបភាព-ការវាយតម្លៃនៃកណ្ឌគម្ពីរលោកុប្បត្តិ

1. រូបភាពទាំងមូល-ព្រះគម្ពីរលោកុប្បត្តិបានចាប់ផ្តើមដោយការបើកសំដែងពីការស្តារឡើងវិញនៃរូបឆ្លុះរបស់ ព្រះ។

2. ត្រីកោណ-ការបង្កបង្កើតជាកិច្ចការដែលព្រះបានចាប់ផ្តើមជាមួយគោលការនៃស្ថានសួគ៌អំពីព្រះត្រៃឯក។

3. រូបភាពប្រាំមួយដែលពង្រីកត្រីកោណ-ការបង្កបង្កើតផ្ទៃមេឃនិងផែនដីដែលពេញដោយលក្ខណៈរបស់ព្រះ។

1) រូបភាពទីមួយ និង ទីបួន-ការបង្កបង្កើតថ្ងៃទីមួយ (ពន្លឺ) និង ការបង្កបង្កើតនៅថ្ងៃទីបី (ព្រះអាទិត្យ ព្រះចន្ទ និង ផ្កាយ)

2) រូបភាពពីរ និង ទីប្រាំ-ការបង្កបង្កើតនៅថ្ងៃទីពីរ (ផ្ទៃមេឃនិងផែនដី) និង ការបង្កបង្កើតនៅថ្ងៃទីបួន (គ្រប់ប្រភេទនៃសត្វស្លាប និង ត្រី)។

3) រូបភាពទីបី និង រូបភាពទីប្រាំមួយ-ការបង្កបង្កើតនៅក្នុងថ្ងៃទីបី (ផ្ទៃដី) និង ការបង្កបង្កើតនៅថ្ងៃ ទីប្រាំមួយ (សត្វ រុក្ខជាតិ និង មនុស្ស)។

4. រូបភាពដប់ខាងក្រោម និង ព្រួញនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ-ពូជពង្សទាំងដប់នៅក្នុងព្រះគម្ពីរ លោកុប្បត្តិ។

1) រូបភាពទីមួយ-ការបង្កបង្កើតផ្ទៃមេឃ និង ផែនដី

2) រូបភាពទីពីរ-ពូជពង្សរបស់អ័ដាម

3) រូបភាពទីបី-ពូជពង្សរបស់ណូអេ

4) រូបភាពទីបួន-ពូជពង្សរបស់លោកណូអេ និង កូនៗរបស់គាត់

5) រូបភាពទីប្រាំ-ពូជពង្សរបស់សឹម

6) រូបភាពទីប្រាំមួយ-ពូជពង្សរបស់តេរ៉ា

7) រូបភាពទីប្រាំពីរ-ពូជពង្សរបស់អ៊ីស្មាអែល

8) រូបភាពទីប្រាំបី-ពូជពង្សរបស់អ៊ីសាក់

9) រូបភាពទីប្រាំបួន-ពូជពង្សរបស់អេសាវ

10) រូបភាពទីដប់-ពូជពង្សរបស់យ៉ាកុប។

# មេរៀនទី1៖ ការវាយតម្លៃនៃព្រះគម្ពីរលោកុប្បត្តិ

1. ជីវៈប្រវត្តិ និង ការវាយតម្លៃ

ព្រះគម្ពីរលោកុប្បត្តិបានចាប់ផ្តើមជាមួយ “ហើយកាលដើមដំបូងឡើយ (ប្រ៊ីស្ទីត)។” ទាំងហាសិបជំពូកបើក បង្ហាញ ពីប្រវត្តិសាស្រ្តនៃការបង្កបង្កើតរហូតដល់ប៉មបាបិល (១-១១) ហើយក៏បានបើកបង្ហាញពី ប្រវត្តិសាស្រ្ត របស់មនុស្សចាប់ពីលោកអ័ប្រាហាំរហូតដល់យ៉ូសែប (១២-៥០)។ ១១ ជំពូកដំបូងណែនាំអំពី ព្រះដ៍ ជាព្រះ អាទិករ ដើមដំបូងនៃជីវិត ដើមដំបូងរបស់អំពើរបាប ដើមដំបូងនៃការកាត់ទោស ដើមដំបូងនៃ ក្រុមគ្រួសារ ដើមដំបូងនៃការថ្វាយបង្គំរូបព្រះក្លែងក្លាយ និង ដើមដំបូងនៃសេចក្តីសង្គ្រោះ។ ហើយផ្នែកដែល នៅសល់ផ្តោត ទៅលើពូជពង្សទាំងបួន: លោកអ័ប្រាហាំ លោកអ៊ីសាក់ លោកយ៉ាកុប និង លោកយ៉ូសែប ដែលជាបិតា នៃសេចក្តីជំនឿ។ ចាប់ពីពួកគាត់មកសាសន៍អ៊ីស្រាអែលបាន ចាប់ផ្តើមមាន ឡើងនៅលើផែនដី ហើយព្រះគ្រិស្ទ ជាព្រះអម្ចាស់របស់ យើងបានប្រសូតចេញពីពួកគេមកនៅក្នុងលោកិយ នេះ។

1) ចំណាងជើង:

**2**)គោលបំណង: កណ្ឌាគម្ពីរនេះផ្តោតសំខាន់ទៅលើការស្តាឡើងវិញនៃរូបឆ្លុះរបស់ព្រះតាមរយៈគោល ការណ៍ការរៀបចំនៃសេចក្តីប្រោសលោះ ដែលពួកកូនចៅអ៊ីស្រាបានចេញមកពីស្រុកអេស៊ីពមក ដើម្បីនឹង សំរេច បំពេញតាម គោលការរបស់ព្រះ។

**3**) ការសង្ខេប:

| ផ្ទៃរឿង | ព្រិត្តិការណ៍ធំៗទាំងបួន | | | | មនុស្សដែលអស្ចារ្យទាំងបួន | | |
|---|---|---|---|---|---|---|---|
| ការបែងចែក | ការបង្កបង្កើត ១- ២ | ការធ្លាក់ចុះ ៣ - ៥ | ទឹកជំនន់ ៦ - ៩ | ជាតិសាសន៍ ១០ - ១១ | អ័ប្រាហាំ ១២- ២៤ | អ៊ីសាក់ ២៥- ២៦ | យ៉ាកុប ២៧ - ៣៦ |
| ចំណងជើង | យុគប្រវត្តិសាស្រ្ត (ដើមដំបូងនៃមនុស្សជាតិ) | | | | ប្រវត្តិរបស់ពូជាសាសន៍ (ដើមដំបូងរបស់ពួកហេព្រើរ) | | |
| ទីកន្លែង | ជាង២០០០ឆ្នាំមុន (២០% នៃព្រះគម្ពីរលោកុប្បត្តិ) | | | | ប្រហែលជាជាង ៣០០ ឆ្នាំមុន (៨០% នៃលោកុប្បត្តិ) | | |

4) ការពន្យល់

(1) ការបង្កបង្កើតផ្ទៃមេឃ និង ផែនដី (១:១-២:៣)

អំណាចចេស្តាទោល

ល្អហើយ

ហេស្សាមើរុន-ទ្រឹស្តីនៃការបង្កបង្កើតថ្ងៃទីប្រាំមួយ

ហេឡូហ៊ីម-ព្រះ ជាប្រភពនៃអំណាច

ព្រះគម្ពីរលោកុប្បត្តិជំពូកមួយមិនមែនជាការប្រឌិតរឿងព្រេងនោះទេ។

(2) កំណើតនៃផ្ទៃមេឃ និង ផែនដី ២:៤-៤:២៦

1] "ទាំងនេះជាជំនាន់នៃផ្ទៃមេឃ និង ផែនដី" (១១ដង)

2] ២:៤-៤:២៦ មិនមែនជាការកត់ត្រាអំពីការបង្កបង្កើតទ្វេនោះទេ ប៉ុន្តែជាសភាពដើមរបស់មនុស្ស-ការបង្កើត និង ប្រវត្តិសាស្រ្តរបស់មនុស្ស។

- ២:២៤ — "ដោយហេតុនោះបានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធ វិញ ហើយអ្នកទាំងពីរនោះនឹងត្រឡប់ជាសាច់តែមួយសុទ្ធ។"
- អត្ថន័យទាំងមូលនៃជំពូកទី ២២ បានផ្តល់ពីរបៀបបង្កើតសួនច្បារអេដែន។
- រូបធាតុដើមនៃការបង្កបង្កើតរបស់ព្រិត្តិការណ៍មិនបានលេចឡើងនៅក្នុងជំពូកទីពីរទេ។

3] ការជំទាស់មួយមិនបានស្ថិតស្ថេរនៅចន្លោះជំពូក១ និង ជំពូក២។

- លំដាប់លំដោយនៃការបង្កបង្កើត
- គោលគំនិតរបស់ព្រះអម្ចាស់

**4]** ជំពូកទីបីមិនមែនជារឿងប្រឌិតទេ ប៉ុន្តែជាហេតុការណ៍ជាក់ស្តែងនៅក្នុងប្រវត្តិសាស្ត្រ។
**5]** គោលបំណងជំពូកទី៤បានបង្ហាញពីការផ្តេផ្តាចិត្តយ៉ាងរហ័សនៃអំពើរបាប។

(3) ពូជពង្សរបស់អ័ដាម ៥:១ - ៦:៨

**1]** ៤ៈ:១៧ ខាងក្រោម ពូជពង្សរបស់កាអ៊ីន ៤ៈ:១៧ ត្រូវបានដាក់ចូល។ ជំនាញនៃការសរសេររបស់លោកម៉ូសេ (២៥ៈ:១២-១៩)។

**2]**មានចំនុចស្រដៀងគ្នានៅក្នុងឈ្មោះពូជពង្សដែលបានលេចឡើង នៅក្នុងជំពូក ៤-៥។

**3]** ជំពូកទី៥ មិនមែនជាគោលបំណងដែលបានបង្ហាញនៅក្នុងរបាក្យត្រ។

**4]** ៦:១-៨- ជាសេចក្តីផ្តើមដែលបានបង្ហាញពីអំពើរបាបរបស់មនុស្ស ដែលបាននាំយកទឹកជំនន់នៃការកាត់ទោស និង សេចក្តីសុចរិតរបស់លោកណូអេ។

(4) ពូជពង្សរបស់លោកណូអេ ៦:៩-៩:២៩

1] មូលហេតុនៃទឹកជំនន់នោះជាការសំរេចបំពេញនៃអំពើរបាបរបស់មនុស្សនៅក្នុងពិភពលោក។

2] គោលបំណងរបស់ទឹកជំនន់គឺដើម្បីនឹងបំផ្លាញមនុស្សជាតិទាំងអស់។

3] ចំនុចដែលផ្តោតសំខាន់ទៅលើនៅក្នុងអត្ថបទនោះជាសេចក្តីសង្គ្រោះដល់អ្វីដែលនៅសេសសល់។

4] ការស្តាប់បង្គាប់របស់លោកណូអេ
នៅក្នុងខែទីពីរ នៅក្នុងថ្ងៃទី ១៧ ពួកគេបានចូលទៅក្នុងទូក (៧:១១-១២)

ភ្លៀងធ្លាក់រយៈពេល៤០ថ្ងៃដោយឥតឈប់ឈរ

ទឹកនៅលើផែនដីអស់រយៈពេល ១៥០ ថ្ងៃ។

ប្រាំពីរជំហ៊ានក្នុងការកាត់បន្ថយទឹកពីលើផែនដី។

**5]** ទឹកជំនន់មាននៅពាសពេញផែនដីទាំងមូល។

6]ព្រះអម្ចាស់បានអះអាងថាទ្រង់នឹងមិនបំផ្លាញផែនដីដោយសារទឹកទៀតឡើយ ហើយផែនដីនឹងបានពរដោយ សារសិម។

(5) ពូជពង្សរបស់កូនចៅលោកណូអេ ១០:១-១១:៩

1] គ្រប់ទាំងមនុស្សជាតិនឹងត្រូវខ្ចាត់ខ្ចាយទៅគ្រប់ទីកន្លែងទាំងអស់នៅលើផែនដី។

2] ជំពូកទី១០ និង ទី១១មានអ្នកនិពន្ធតែមួយ។

(6) ពូជពង្សរបស់សិម ១១:១០-២៦

1] ស្រដៀងនឹងជំពូកទី៥ ពូជពង្សនៃរាស្ត្ររើសតាំងរបស់ទ្រង់។

(7) ពូជពង្សរបស់តេរ៉ា

1] ជីវិតរបស់អ័ប្រាហាំ ជាពួយុកោ

គាត់បានទទួលទឹកដីដូចការសន្យា

គាត់ទទួលកូនចៅយ៉ាងច្រើន

គាត់បានទទួលការសន្យានៃព្រះពរសំរាប់សកលលោកទាំងមូល។

2] តើយើងអាចបកស្រាយជីវិតរបស់អ័ប្រាហាំដោយរបៀបណា?

(8) ពូជពង្សរបស់អ៊ីស្មាអែល ២៥:១២-១៨

(9) ពូជពង្សរបស់អ៊ីសាក់ ២៥:១២-១៨

1] ភស្តុតាងនៃបុរាណវិទ្យា

ណូស្ស៊ូ (ធូឈីទីឡា)

ធាម៉ៀ

ណាឈីរ៉ា

យ៉ាកុប (ព្រះបានថៃរក្សារ)

(10) ពូជពង្សរបស់អេសាវ ៣៦:១-៣៧:១

**1**] ៣៦:៣១

មានភស្តុតាងដែលថាស្តេចរបស់អ៊ីដំមគឺជាមនុស្សដូចជាលោកម៉ូសេ។ (ប៉ៃតង)

(11) ពូជពង្សរបស់យ៉ាកុប ៣៧:២-៥០:២៦

**1**] ជំពូក ៤៩ មិនមែនជាពាក្យរបស់យ៉ាកុបទេ។

**2**] ឥរិយាបថដែលមានពរនៃការទស្សទាយរបស់យ៉ាកុប។

[សំនួរទី1] ចូរអានមេរៀនទីមួយម្តងទៀត រួចចូរឆ្លើយនឹងសំនួរដូចតទៅនេះ។

1. ចូរឱ្យឈ្មោះបុគ្គលសំខាន់ៗទាំងបួន ជាអ្នកនៅក្នុងព្រះគម្ពីរលោកុប្បត្តិ។ — អ័ដាម ណូអេ អ័ប្រាហាំ អ៊ីសាក់ និង យ៉ាកុប។

2. ចូរនិយាយត្រួសៗពីគ្រោងរបស់ព្រះគម្ពីរលោកុប្បត្តិ។ — ជំពូក ១-១១: យុគប្រវិត្តិសាស្ត្រ ១២-៥០: ប្រវត្តិពួកព្ទយុកោ។

3. ចូរអានព្រះគម្ពីរលោកុប្បត្តិ ១:២៦-២៧ ហើយអនុវត្តគោលការណ៍ ពបសឧប ចេញពីអត្ថបទ។

(1)"ដូចជារូបយើង" (២៦-២៧)-ព្រះត្រៃឯករូបឆ្លុះដើមរបស់មនុស្ស។ = ខ្ញុំគួរតែស្វែងរករូបឆ្លុះដើមរបស់ ខ្ញុំចេញពី ព្រះត្រៃឯក: ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ សេចក្តីសុចរិត សេចក្តីមេត្តាករុណា និង ភាពស្មោះត្រង់របស់ទ្រង់ គឺជារូបឆ្លុះដ៏ពិតរបស់ខ្ញុំ។ ការស្តារឡើងវិញនៃរូបឆ្លុះ របស់ព្រះត្រូវតែបានរកឃើញដោយ ការតភ្ជាប់ទៅនឹងបទគម្ពីរ ដែលជាប្រភពនៃធាតុទាំងបី (ម៉ាថាយ ២៣:២៣)។

(2)"ឱ្យមានអំណាចលើ..."(២៦)-ព្រះដែលជាអ្នកតែងតាំងមនុស្សឱ្យបានក្លាយជាអ្នកបំរើនៅក្នុងគ្រប់របស់ ទាំងអស់ ។ = ខ្ញុំមិនមែនជាម្ចាស់ទេ ប៉ុន្តែខ្ញុំជាអ្នកគ្រប់គ្រងលើរបស់ទាំងអស់។ក្នុងនាមជាអ្នកគ្រប់គ្រប់ ខ្ញុំគួរតែរស់នៅក្នុងភាព ជាម្ចាស់នៅក្នុងជីវិតរបស់ខ្ញុំ។ ដោយសារតែខ្ញុំត្រូវតែរាយការពីអ្វីដែលខ្ញុំបានធ្វើ ទៅកាន់ ព្រះអម្ចាស់ជាម្ចាស់ដ៏ពិត និង និងឹទ្រង់នឹងវាយតម្លៃពីកិច្ចការនោះ។ ខ្ញុំត្រូវតែដឹងពីភាពជាអ្នក បំរើនៅក្នុងពេល របស់ខ្ញុំ រូបកាយរបស់ខ្ញុំ អំណោយទានរបស់ខ្ញុំ និង សម្ភារៈរបស់ខ្ញុំ។

(3) "ជាប្រុសជាស្រី" — "ព្រះបានបង្កើតមនុស្សជាប្រុសជាស្រី" = វប្បធម៌មនុស្សខ្ទើយបានចូលមក នៅក្នុងក្រុម ជំនុំ ប៉ុន្តែយើងគួរតែឈរមុាំនៅលើរបៀបរៀបរយនៃការបង្កបង្កើត។ ព្រះជាម្ចាស់មិនបាន បង្កើតភេទទីបីនៅលើ ផែនដីនោះ ទេ។

2) អំពើរបាប-គ្មាន

3) ការសន្យា-គ្មាន

4) ឧទាហរណ៍-ឧទាហរណ៍ដែលព្រះទ្រង់បានធ្វើការយ៉ាងមានតម្លៃជាច្រើនជាងមនុស្ស (26)=ខ្ញុំគួរតែស្មោះ ត្រង់នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ដែលបានដាក់មកសំរាប់ខ្ញុំ។ កិច្ច

ការនៅក្នុងជីវិតខ្ញុំ ហើយវានឹងដើរខាង មុខនៃជីវិតរបស់ខ្ញុំ។

5) បញ្ញាត្តិ-គ្មាន

សេចក្តីពិត- ខ្ញុំត្រូវបានបង្កើតមកនៅក្នុងរូបឆ្លុះរបស់ព្រះគួរតែរស់នៅសំរាប់កិច្ចការដែលទ្រង់បានផ្តល់មកខ្ញុំ។ ពីព្រោះ ខ្ញុំកើតមក ដោយសារតែកិច្ចការនោះ។

## មេរៀនទី២ គោលគំនិតនៃរូបភាព-ព្រះអម្ចាស់នៃការបង្កបង្កើត

**1.** ត្រីកោណ-ព្រះអាទិករគឺជាដានជើងផ្ទាល់នៃព្រះត្រៃឯក។

**1)** ផ្នែកខាងលើ-ព្រះវរបិតាមានបន្ទូលថា

**2)** ផ្នែកដែលត្រូវ-ព្រះផ្ទាល់ទ្រង់ជាព្រះបន្ទូល

**3)** ផ្នែកខាងឆ្វេង-ព្រះវិញ្ញាណបរិសុទ្ធបានបង្កើតព្រះបន្ទូល ដោយសេចក្ដីស្រលាញ់របស់ទ្រង់ (មេរាហាផេត)

**2.** កិច្ចការនៃការបង្កបង្កើតបង្ហាញពីសញ្ញានៃការបង្កបង្កើតសារជាថ្មី (ការប្រោសលោះ)

**1)** រូបទីមួយតាមរយៈព្រះរាជបុត្រា-ពន្លឺ

**2)** រូបទីពីរតាមរយៈព្រះរាជបុត្រា-ភាពរឹងមាំ

**3)** រូបភាពទីបីតាមរយៈព្រះវិញ្ញាណបរិសុទ្ធ-ទឹក

**3.** ទឹកដីទ្វេត្រូវបានហ៊ុមព័ទ្ធដោយព្រះត្រៃឯក-ព្រះបានបង្កើតគ្រប់របស់ទាំងអស់នៅក្នុងសេចក្ដីសប្បុរស។

**4.** មនុស្សពីរនាក់-ព្រះបានបង្កើតមនុស្សនៅក្នុងរូបឆ្លុះរបស់ព្រះ។

១) ផ្នែកដំបូងនៅក្នុងសញ្ញានៃសេចក្ដីស្រលាញ់នៅក្នុងដើមទ្រូង-សេចក្ដីសុចរិត

២) ផ្នែកទីពីរនៅក្នុងសញ្ញានៃសេចក្ដីស្រលាញ់នៅក្នុងដើមទ្រូង-សេចក្ដីមេត្តាករុណា

៣) ផ្នែកទីបីនៅក្នុងសញ្ញែនសេចក្ដីស្រលាញ់នៅក្នុងដើមទ្រូង-ភាពស្មោះត្រង់

## មេរៀនទី២ ការបង្កបង្កើតរបស់ព្រះ

I. អត្ថបទ: លោកុប្បត្តិ ១:១-៣១

II. ខគន្លឹះ: លោកុប្បត្តិ ១:២

III. ការវាយតម្លៃ:

ច្បាប់របស់ព្រះដែលបានបង្កើតមកដោយគោលការណ៍របស់ព្រះត្រៃឯកដែលបានបង្ហាញពីសិរីល្អរបស់ ព្រះ។ សេដ្ឋកិច្ចត្រូវបានគ្រោងមកដើម្បីបង្ហាញពីសិរីល្អនៃអាណាចក្រដែលនឹងពេញទៅដោយលក្ខណៈ របស់ព្រះ: សេចក្តីសុចរិត សេចក្តីមេត្តាករុណា និង ភាពស្មោះត្រង់។ ទាំងនេះជារូបឆ្លុះរបស់ព្រះនៅក្នុង កាលដំបូងឡើយ នៅក្នុងគោលការណ៍ និង ការសំរេចបំពេញដោយព្រះជាម្ចាស់ផ្ទាល់។ ហើយកិច្ចការ បែបនោះឯង។ ព្រះវរបិតាបានបង្កើតគ្រប់របស់ទាំងអស់ ហើយព្រះរាជបុត្រាផ្ទាល់ ជាអ្នកបង្កើតការ នោះ ហើយព្រះវិញ្ញាណបរិសុទ្ធជាអ្នកសំរេចបំពេញការនោហដោយ ការទ្រទ្រង់ការ នោះនៅក្នុងប្រវត្តិ សាស្រ្ត។ ការបើកសំដែងនៃការបង្កបង្កើតនៅក្នុងព្រះគម្ពីរបានចាប់ផ្តើមដោយ គោលការណ៍សាមញ្ញ “កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃ និង ផែនដី” (១:១)។ នៅក្នុងនោះយើង អាចរៀនថា តើព្រះអាទិករជានរណា លក្ខណៈនៃរបស់ដែលត្រូវបានបង្កើតមកយ៉ាងដូចម្តេច ហើយតើនរណាជាអ្នក ដែលត្រូវបានបង្កើតមកនៅក្នុងរូបឆ្លុះរបស់ព្រះ ដែលជាចំណែកនៃចៅហ្វាយនៅក្នុងការបង្កបង្កើត។

IV. ការពន្យល់:

នៅក្នុងពន្លឺនៃការប្រោសលោះ ហើយដឹងយ៉ាងច្បាស់ពីអត្ថន័យរបស់ព្រះគម្ពីរលោកុប្បត្តិជំពូកទី១។

1. ព្រះអម្ចាស់នៃការបង្កបង្កើត (លោកុប្បត្តិ ១:១-៥)

មនុស្សចូលចិត្តស្វែងរកចំលើយនៅក្នុងគ្រប់ការទាំងអស់នៅក្នុងព្រះគម្ពីរលោកុប្បត្តិ

ដោយសារកណ្ឌគម្ពីរសំរាប់អនុវត្តន៍ នៅក្នុងគ្រប់កិច្ចការទាំងអស់: ពិភពលោក របស់ដែលត្រូវបានបង្កើតទាំងអស់ ក្រុមគ្រួសារ សួនអេដែន អំពើរបាប ការងារ មនុស្សជាតិ ជាតិសាសន៍ ពួកអ៊ីស្រាអែល និង ការសង្គ្រោះជាដើម។ បញ្ហាចម្បងនៃការបង្កបង្កើតគឺត្រូវបាន ដោះស្រាយដោយ លោកុប្បត្តិ ១:១ នៅក្នុងសភាពច្បាស់លាស់។

ខគម្ពីរមួយនោះគឺគ្រប់គ្រាន់សំរាប់ណែនាំអំពីព្រះដែលមានគ្រប់ទាំងអំណាចចេស្តា ជាព្រះដែលបានបង្កើត គ្រប់ របស់ ទាំងអស់ចេញពី នីហីល (គ្មានអ្វីទាំងអស់) ឬ រូប។ ដូចនេះអ្នកប្រាជ្ញដែលមានជីវិតរស់នៅបាប យកនូវប្រេភពមួយ (កាប់ដា) និង ការវិវត្តដែល អាមូបាបានអភិវឌ្ឍន៍ចេញមកជាមនុស្ស ដោយឆ្លងរយៈ ពេលយ៉ាងយូរ ដែលមិនបានអះអាងទេ ដោយគ្រាន់តែជាការស្មានប៉ុណ្ណោះ។ កាន់តែប្រសើរថែមទៀត នោះខគម្ពីរនោះបានបង្ហាញសេចក្តីស្រលាញ់ដែល មានការ បូជារបស់ព្រះវិញ្ញាណបរិសុទ្ធ ជាព្រះដែលធ្វើការយ៉ាង អស្ចារ្យនៅក្នុងការផ្លាស់ប្តូរសេចក្តីងងឹត ភាពទទេរ ជម្រៅ និង ភាពស្មុគស្មាញរបស់ផែនដី ទៅជាពិភព លោក មួយដែលស្រស់បំព្រង។ (១:២) “ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្រប់នៅ លើជំរៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក។” នៅទីនេះ មេរ៉ាហេផេត អត្ថន័យរេរា ជាពាក្យមួយដែល មានលក្ខណៈប្លែកនៃការប្រោសលោះ ដែលទាក់ទងទៅនឹងការសរសេររបស់លោកម៉ូសេ។ គាត់បានប្រើការប្រោសលោះរបស់ពួកអ៊ីស្រាអែល ដោយប្រៀបធៀបទៅនឹងសកម្មភាពរបស់សត្វ ឥន្ទ្រីដែលដាក់កូនខ្លួននៅលើខ្នង និង បង្វឹកពួកវាដោយធ្វើឱ្យ មានការច្របូកច្របល់នៅក្នុងសំបុករបស់វា។ “ឧបមាដូចជាឥន្ទ្រី ដែលដាស់តឿនកូននៅក្នុងសំបុក ក៏ហើរសំរឹងពីលើ រួចត្រដាងស្លាបទទួលកូន ទ្រនៅលើចំអេងឡើង។ ១២ ព្រះយេហូវ៉ាតែ១ព្រះអង្គ ទ្រង់បាននាំលោកឥតមានព្រះដទៃណានៅ ជាមួយឡើយ។ (ចោទិយកថា ៣២:១១-១២)” ដូចជាឥទ្ធិពលរបស់មេមាន់ទៅកាន់ពង នៅពេលដែល វារងចាំពងញាស់មក ព្រះនៃការបង្កបង្កើតមានឥទ្ធិពលដូចនោះទៅកាន់ផែនដីដែលទ្រង់បានធ្វើការនោះ។ នៅក្នុងចិត្តដែលប្លែកហើយកក់ក្តៅរបស់ព្រះត្រៃឯក ដែលជាព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណ បរិសុទ្ធ ពិភពលោកនៃភាពងងឹត ជំរៅ និង សេចក្តីងងឹតត្រូវបានផ្លាស់ ប្តូរទៅជាពិភពលោកដែលមានរបៀប រៀបរយ ជីវិត និង ពន្លឺ។ ពេលដែលព្រះអាឡូហ៊ីម បានប្រកាសព្រះ បន្ទូលរបស់ព្រះ ពិភពនៃពេលវេលា និង លំហរដែលត្រូវបានបង្កើតដោយ ច្បាប់របស់បុគ្គលបីអង្គ នៅក្នុងព្រះតែមួយ។

2. ការបង្កបង្កើតដែលពេញទៅដោយសេចក្តីសប្បុរស (លោកុប្បត្តិ ១:៦-២៣)

ដោយសារព្រះទ្រង់ជាព្រះសប្បុរស ដូចនេះពិភពលោកបានពោរពេញដោយសេចក្តីសប្បុរស។ នៅក្នុងថ្ងៃ ទីមួយ ព្រះបានបង្កើតពន្លឺ។ នៅក្នុងថ្ងៃទីពីរ ផ្ទៃមេឃ ពពក សមុទ្រ។ នៅក្នុងថ្ងៃទីបី ផែនដី និង នៅក្នុងថ្ងៃទីបួន ព្រះអាទិត្យ ព្រះច័ន្ទ និង ផ្កាយ។ ហើយនៅក្នុងថ្ងៃទីប្រាំ ត្រីគ្រប់ប្រភេទ និង បក្សីគ្រប់ប្រភេទ។ ហើយនៅក្នុងថ្ងៃទីប្រាំមួយ ទ្រង់បានបង្កើតសត្វជើងបួន និង មនុស្ស។ នៅពេលដែលទ្រង់បានបង្កើត ទ្រង់បានសព្វព្រះហឫទ័យហើយបានបង្ហាញមកដោយមានបន្ទូលថា "ល្អហើយ"។ ប៉ុន្តែការដែលទ្រង់បាន បង្កើតចុងក្រោយ ទ្រង់មានបន្ទូលថា "ល្អប្រពៃ" ជាភស្តុតាងនៃការបង្កបង្កើតយ៉ាងល្អ។ ដោយសារតែអត្ត សញ្ញាណរបស់ព្រះសេចក្តីសប្បុរស សេចក្តីស្រលាញ់ និង ភាពស្មោះត្រង់ ដែលត្រូវបានដាំឡើងនៅក្នុងរបស់ ដែលបានបង្កើតមក។ គ្រប់របស់ទាំងអស់បានពោរពេញដោយសេចក្តីសប្បុរសរបស់ព្រះ។ ដូចដែលអ្នកសរសេរ ទំនុកដំកើងនៃទំនុកដំកើង ១៩ បានឃើញថាគ្រប់របស់ដែលនៅលើផែនដី បានពេញដោយសិរីល្អនៃសេចក្តី ស្រឡាញ់ និងភាពស្មោះទ្រង់ដ៏នៅអស់ កល្បជានិច្ច។ ថ្ងៃនិយាយទៅកាន់ថ្ងៃ យប់និយាយទៅកាន់យប់ ទោះជា គ្មានសំលេងក៏ដោយ ឬ ក៏គ្មានសំលេងណាក៏ដោយហើយការនោះបានបង្ហាញពីកិច្ចការរបស់ព្រះនៅក្នុងសកល លោកនេះ។ ប្រសិនបើមនុស្សមិន បានធ្វើបាននោះទេ គេនឹងអាចមានអារម្មណ៍ដឹងពីសេចក្តីស្រឡាញ់ និង ភាពស្មោះត្រង់របស់ព្រះយ៉ាង លឿន ហើយសេចក្តីរីករាយ លក្ខណៈដ៏អស្ចារ្យរបស់ទ្រង់ ហើយទ្រង់នឹងធ្វើឱ្យរបផ្ទះរបស់ទ្រង់ថ្មីឡើងជារៀងរាល់ថ្ងៃ។ តើការបង្កបង្កើតនៅក្នុងថ្ងៃទីប្រាំមួយមានការសង្ឃឹមអ្វីពីកិច្ចការនៃការ ប្រោសលោះការបង្កបង្កើតជាថ្មី? សាវ័ក យ៉ូហាន និង សាវ័កប៉ូលបានឃើញការប្រោសលោះ ទៅជាប្រវត្តិ សាស្ត្រនៃកិច្ចការរបស់ការបង្កបង្កើត នៅក្នុងនោះ។ យើងអាច រកឃើញរូបតំណាងមួយចំនួននៃការប្រោស លោះនៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក១។

1) ពន្លឺ (លោកុប្បត្តិ ១:១-៥)-ការបង្កបង្កើតរបស់ព្រះជាពន្លឺ។ ពន្លឺ "ហា អូល" នៅក្នុងភាសាហេព្រើរ ជាប្រភព នៃពន្លឺដែលត្រូវបានបែងចែកពីព្រះអាទិត្យ (យ៉ូប ៣៨:១៩-២០ អេសាយ ៣០:២៦ កិច្ចការ ២៦:១៣)។ ដំបូងពន្លឺជាពន្លឺ ដែលពិត ដែលចង្អុលទៅកាន់ព្រះគ្រិស្ទ ជាប្រភពនៃរបស់ទាំងអស់ (កូល៉ុស ១:១៧)។ ដូចនេះគ្រិស្ទានមានភាពពិតរបស់ពន្លឺ

ហើយបានក្លាយជាពន្លឺនៃលោកិយដែលផ្លាស់ប្តូរពួកគេទៅជា ជីវិតចេញ ពីសេចក្តីងងឹត។ ទីពីរ ព្រះអេឡូហ៊ីម ជាអង្គដែលចង្អុល បង្ហាញពីអំណាចចេស្តា ពន្លឺដែលបានបង្កើត មក។ លែកាម៉ូសេប្រើពាក្យអាឡូហ៊ីមច្រើនជាជាងយេហូវ៉ា ដែលសង្កត់ធ្ងន់លើ អង្គដែលមិនអាចប្រៀប ធៀបជាមួយរូប ព្រះក្លែងក្លាយបាននោះឡើយ។ ទ្រង់ជាព្រះនៃលក្ខណៈសម្បត្តិដែលទ្រង់ជាបន្ទូលផ្ទាល់ ដែលត្រូវបានមានបន្ទូលមក ហើយព្រះវិញ្ញាណបរិសុទ្ធទ្រង់ជាអ្នកបង្កើត ដែលធ្វើឱ្យ ព្រះបន្ទូលដែលចេញ មកទៅជា របស់គ្រប់យ៉ាង ហើយបានធ្វើឱ្យវាទាក់ទងគ្នា។ ការនេះត្រូវពឹងលើព្រះគ្រិស្ទ ដែលបានក្លាយទៅ ជាពេលវេលា និង ចន្លោះនៃប្រវត្តិសាស្ត្រ។ ដូចជាជាពួកហោរាបានឃើញផ្កាយ គ្រិស្ទានដែលមានពន្លឺពិត ប្រាកដមានព្រះពរដ៏ពិតប្រាកដ ដោយសារ ពួកគេរស់នៅដោយសារព្រះចេស្តា។

2)ការបង្កបង្កើតនៃការវាយសាយ (លោកុប្បត្តិ១:៦-៨)-តើការបង្កបង្កើតនៃការរីករាយសាយនៅក្នុង ថ្ងៃ ទីពីរ មានន័យយ៉ាងណា?ដំបូងការរីករាយសាយគឺជាចន្លោះដែលអាចបែងចែករវាងផ្ទៃមេឃនិងផែនដី។ ការរីករាយសាយ “រ៉ាឆៀ” នៅក្នុងភាសាហេព្រើរមានន័យថា ការបុកទង្គិច ការបំបែកមាស ឬ ទឹកកក។ នាំន័យថាលំហរដែលនៅទទេពោរពេញដោយអ្វីមួយ។ សកម្មភាពនេះដែលបំបែក និង ធ្វើឱ្យស្របគ្នានៃលំហរ នេះជារូបសញ្ញាដំបូងដែលប្រាប់ពីលក្ខណៈនៃការសង្គ្រោះនៅក្នុងព្រះគម្ពីរ។ នៅគ្រប់ទីកន្លែងទាំងអស់ដែលព្រះ គ្រិស្ទមកដល់ ការបែកបាក់ និង ការរួបរួម នឹងត្រូវបានផ្លាស់ប្តូរ (លោកុប្បត្តិ ៣:១៥ យ៉ូហាន ៥:២៤)។ ទីពីរការរឹងម៉ាំដែលត្រូវបានបំបែក ទឹកនៅខាងលើ-ពពក-នឹងទឹកដែលនៅខាងក្រោម-សមុទ្រ-គឺជាប្រវត្តិ សាស្ត្រដែលជាពូជរបស់ត្រី និង ពូជសត្វស្លាបដែលអាចរស់នៅបាន (២០-២១)។ ការនេះបានបង្ហាញ ពីសេចក្តីស្រឡាញ់យ៉ាងច្បាស់របស់ព្រះ ដែលទ្រង់មានទំនួលខុស ត្រូវការស្លៀកពាក់ ការបរិភោគ និង ការស្នាក់នៅនៃរបស់ដែលទ្រង់បានបង្កើតមក។ ហើយក៏បានបង្ហាញពីសញ្ញាដែលព្រះបានព្រមានទាស់នឹងការ ថ្វាយបង្គំរូបព្រះក្លែងក្លាយនៃរបស់របរ ហើយបានធ្វើឱ្យពួកគេស្វែងរកអាហារដោយ ការរស់ នៅដោយទុកព្រះ ជាកណ្តាលនៅក្នុងជីវិតជារៀងរាល់ថ្ងៃ។

3) ការលេចឡើងរបស់ផ្ទៃដីគោក (លោកុប្បត្តិ ១:៩-១៣)-ការបង្កបង្កើតនៃទ្វីបដែលអណ្តែតឡើងលេច ចេញមកពីជំរៅទឹក ហើយការនេះក៏មានអត្ថន័យនៃការសង្គ្រោះផងដែរ។ ទីមួយជំរៅទឹកជាតំណាងរបស់លោកិយ និង អំពើរបាបរបស់លោកិយ។ ការបង្កបង្កើតបាន

ទាញយកដីគោកមកពីផ្ទៃទឹកចេញពីសភាពនៃការច្របូកច្របល់ និង ភាពទទេ។ មើលទៅហាក់ដូចជាសញ្ញាមួយយ៉ាងច្បាស់លាស់ដែលព្រះបានសង្គ្រោះយើងចេញពីស្ថាននរគ នៃសេចក្តី ស្លាប់និងបណ្តាសារដោយសារតែអំពើបាបរបស់យើងផ្ទាល់។ ព្រះដែលបានសង្គ្រោះយើងចេញពីទឹកនៃ អំពើបាបដ៏ អាក្រក់ទ្រង់ជាព្រះអាទិករដែលអាចសង្គ្រោះយើងចេញពីគ្រប់ទាំងបញ្ហាទាំងអស់។ ទីពីរទ្រង់បាន សង្គ្រោះយើងដោយ ព្រះបន្ទូលរបស់ទ្រង់។ ព្រះបន្ទូលដែលព្រះបានប្រកាសចេញមកជាឧបករណ៍ដែល សំខាន់របស់ព្រះត្រៃឯក។ តាមរយៈ បញ្ញាត្តិរបស់ទ្រង់ ព្រះបាន បង្កើតរុក្ខជាតិគ្រប់ប្រភេទនៅលើផែនដី។ នៅទីនេះគ្រប់ប្រភេទទាំងអស់សំដៅទៅលើភេទ។ ព្រះបន្ទូលដែលបានបង្កើត ស្បែនរបស់រុក្ខជាតិជាគ្រាប់ ពូជរបស់ធម្មជាតិ និង សតិបញ្ញា និង ការបើកសំដែងនៃការសង្គ្រោះ ព្រះគម្ពីរ។ ព្រះបន្ទូលនេះ ជាជីវិតរបស់គ្រិស្ទាន។ ទីបីព្រះបានបង្កើតផែនដី ដែលបានក្លាយជាប្រវត្តិសាស្ត្រនៃគ្រប់ទាំងរុក្ខជាតិ បានបង្កើតដូចនេះដើម្បី ឱ្យផែនដីបានមានអំណរនិងជីវិតយ៉ាង ពេញបរិបូរ ដោយចិត្តដែលរស់ពីស្លាប់ឡើងវិញ របស់យើង ដែលបានស្លាប់ដោយសារអំពើរបាប និង ការពុករលួយ។ ដូចនេះយើងគួរតែអនុញ្ញាតឱ្យព្រះគ្រិស្ទ ដឹកនាំលើចិត្តរបស់យើង។

3) ពន្លឺនៅលើផ្ទៃមេឃ (លោកុប្បត្តិ ១:១៤-១៩)-ការបង្ករបង្កើតដែលត្រូវបានបង្កើតឡើងនៅក្នុង ថ្ងៃទីបួន គឺជា ពន្លឺនៅលើមេឃ។ ដោយសារតែពន្លឺទាំងនេះ រដូវការទាំងបួនត្រូវបានគ្រប់គ្រង ហើយជាក់លាក់ដោយឯកឯង។ ទីមួយ ព្រះអាទិត្យ ព្រះច័ន្ទ និង ផាយ គ្មានភាពជាព្រះឡើយ។ ទាមរយៈប្រវត្តិសាស្ត្រ មានការថ្វាយបង្គំព្រះអាទិត្យ ព្រះច័ន្ទ និង ផាយ ដែលចេញមកពីការមិនអើរពើរ ចំពោះគោលបំណងដែលពួកគេគ្រប់គ្រងចង្វាក់នៃជីវិត។ ពួកគេគ្រាន់តែជារបស់ ដែលត្រូវបានបង្កើតមកដោយ សាមញ្ញរបស់ព្រះប៉ុណ្ណោះ (១៤)។ ពន្លឺរបស់ពួកវាផ្តោតទៅ លើផែនដី និង ដើម្បីគ្រប់គ្រង ពេលវេលា (១៥)។ គួរឱ្យភ្ញាក់ផ្អើលណាស់ដែលការប្រោសលោះរបស់យើង ត្រូវបានសំរេចបំពេញដោយសារការយាង មករបស់ព្រះ គ្រិស្ទនៅក្នុងការបន្ទាបអង្គទ្រង់។ ទីពីរ ភាពស្ងប់ស្ងាត់ នៃច្បាប់របស់ផ្កាយធ្វើឱ្យយើង ផ្សៀងត្រជៀកមក ផ្តោតលើព្រះអាទិករទៅវិញ (១៦)។ ទ្រង់បានធ្វើឱ្យ យើងបានរស់នៅក្នុងច្បាប់របស់ព្រលឹងវិញ្ញាណ ដែលព្រះអាទិត្យ ក៏អាចនឹងចុះចូលសំរាប់ការប្រោសលោះរបស់យើង (យ៉ូស្វេ ១០:១៣ អេសាយ ៣៨:៨)។ គ្រិស្ទានដែលបានសង្គ្រោះ ចេញពីអំពើរបាបដោយសេចក្តីជំនឿរស់នៅក្នុង ព្រះគ្រិស្ទ ដែលជាពន្លឺដែលភ្លឺជាង ពន្លឺដែលបាន

បង្កើតមក។

5) ការបង្កបង្កើតប្រភេទសត្វត្រី និង សត្វបក្សី (លោកុប្បត្តិ ១:២០-២៣)-ការបង្កបង្កើតនៅក្នុងថ្ងៃទីប្រាំ ដែលទាក់ទងនឹងការបង្កបង្កើតនៅក្នុងថ្ងៃទីពីរ ជាប្រភេទសត្វត្រី និង ប្រភេទសត្វស្លាប។ តើអ្វីទៅជាការបង្ករ បង្កើតនៅទីនេះ? ទីមួយធាតុដែលមានជីវិតផ្សេងៗទៀតមានការផ្ទុយគ្នាទៅនឹងជីវិតរបស់រុក្ខជាតិដែលបានបង្កើត មក(២០)។ ការស្វែងរកព្រះគុណដែលព្រះបានរៀបចំបានធ្វើឱ្យយើងចេះផ្តោតទៅលើការព្យាបាលពេញបរិបូរនៃ ការប្រោសលោះ (អេសេគាល ៤៧:១២)។ ទីពីរ ការបង្កបង្កើតទង្វឹងចាំការបង្កបង្កើតសារជាថ្មីមកកាន់ យើងដោយសារ បាប នៅក្នុង២ ១ ត្រូវបានបង្ហាញមកម្តងទៀតនៅទីនេះ (២១)។ គារអភិវឌ្ឍនៃការលូត លាស់ចង្អុលទៅកាន់តួអង្គនៃសញ្ញាដែលតំណាងឱ្យ ការកើតជាថ្មីនៃការប្រោសលោះ (២កូរិនថូស ៤:១៦)។ ទីបី ព្រះបានប្រទានព្រះពររបស់ទ្រង់ដំបូងនៅទីនេះ (២២)។ ព្រះអង្គទ្រង់ផ្ទាល់បានប្រទានពរដល់ពួកគេ ដើម្បី ផ្តាច់ពួកគេចេញពីគំនិតដែលថារបស់ទាំងអស់រស់នៅដោយសារតួនាទី ខ្លួនឯងដែលមាននៅក្នុងពួកគេ។ មនុស្សដែល មានប្រាជ្ញាដ៏ពិតប្រាកដ ផ្តោតគំនិតទៅលើកិច្ចការរបៀបរៀបរយនៃ ការបង្កបង្កើតរបស់ទ្រង់ ហើយរៀន ពីការទាំងនោះដោយមានចិត្តបន្ទាបចុះនៅក្នុងប្រាជ្ញវិទ្យាដែលទទេនៃការវិវត្ត។

អ្នកសរសេរទំនុកដំកើងដែលបានរកឃើញពីជំរៅនៃការបង្កើត និង ការបង្កើតឡើងសារជាថ្មីបាន ច្រៀងទៅកាន់ ព្រះជាម្ចាស់ និង សរសើរព្រះអម្ចាស់ពីសេចក្តីសប្បុរសនិងសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេររបស់ទ្រង់ នៅក្នុងទំនុកដំកើង ១០៧:១។ លែកាសាវ័កប៉ូលក៏បានអះអាងថាព្រះមានលក្ខណៈជាព្រះរបស់ទ្រង់ អំណាចចេស្តានៅក្នុងគ្រប់របស់ទាំងអស់ហើយរបស់ទាំងនោះមិនអាចរកអ្វីមកថ្លែងសរសើរ ឬ ច្រៀងដល់ ទ្រង់បានឡើយ នៅក្នុងរ៉ូម ១:២០-២១។ ពាក្យថា“បានមានបន្ទូល” ជាព្រះគ្រិស្ទពីមុនពេលចាប់កំណើត (យ៉ូហាន ១:៣)។ ជារបស់ព្រះគ្រិស្ទដូចនេះយើងមិន អាចធ្វើអ្វីបានក្រៅពីការសរសើរដំកើងការប្រោសលោះដ៏ពេញដោយ អាថ៌កំបាំង។ យើងដែលជាអ្នកបានសង្គ្រោះចេញ ពីអំពើរបាបដ៏អាក្រក់អរព្រះគុណដល់សេចក្តីសប្បុរស និងសេចក្តីស្រឡាញ់របស់ទ្រង់។ យើងក៏បានរៀនពីការអរព្រះ គុណ និងការបន្ទាបខ្លួនដោយសារទង្វើបែបនេះ ត្រូវតែជាការឆ្លើយតបរបស់អស់ទាំងអ្វីៗដែលបានបង្កើតមក។

3. រូបឆ្លុះរបស់ព្រះ (លោកុប្បត្តិ ១:២៦-៣១)

ជាទូទៅមនុស្សត្រូវបានបង្កើតមកក្នុងរូបមួយដែលប្លែកដែលផ្ទុយទៅនឹងរបស់ផ្សេងៗទៀត ដោយសារតែ មនុស្សត្រូវបានបង្កើតមកដើម្បីនឹងប្រមូលផ្តុំរូបឆ្លុះរបស់ព្រះ។ អត្ថន័យដែលត្រូវបាន បង្កើតនៅក្នុង រូបឆ្លុះរបស់ព្រះមិនមែនដោយ ធាតុផ្នែកខាងក្រៅនោះទេ ប៉ុន្តែជាធាតុខាងក្នុងនៃអត្តចរិករបស់ព្រះវិញ: សេចក្តីសុចរិត សេចក្តីមេត្តាករុណា និង សេចក្តីស្មោះត្រង់ (អេភេសូ ៤:២៤)។ ឌូចនេះព្រះបង្ហាញ លក្ខណៈរបស់ទ្រង់នៅក្នុងគ្រប់ទាំងរបស់ទាំងអស់ ឬក៏ផែនដីនេះ ហើយជាពិសេសនោះទ្រង់បានបង្ហាញព្រះ ហឫទ័យរបស់ទ្រង់តាមរយៈមនុស្ស។ ទោះបីជាមនុស្ស ពុករលួយមិនអាចបង្ហាញពីរូបឆ្លុះរបស់ព្រះក៏ដោយ ប៉ុន្តែបែជាជំនួសដោយរូបឆ្លុះរបស់សាតាំងវិញ។ ដូចនេះមនុស្សដែលត្រូវបានក្លាយជាងងឹតដោយសារអំពើបាប នឹងត្រូវបានស្តាឡើងវិញ ដោយគ្រាន់តែការជឿដល់ ព្រះគ្រិស្ទតាមរយៈសេចក្តីជំនឿនោះគេនឹងបានផ្លាស់ប្តូរ បន្តិចម្តងៗនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។

នៅថ្ងៃនេះ ការផ្លាស់ប្រែរបស់វប្បធម៌និងពត៍មានសង្គម ដោយគ្មានការស្តារឡើងវិញនៃរូបឆ្លុះ របស់ព្រះនឹងក្លាយ ទៅជាការលេងសើចយ៉ាងពិតប្រាកដ។ ការផ្លាស់ប្រែដ៏ពិតប្រាកដ និង ការផ្លាស់ ប្រែជាថ្មីគួរតែពឹងលើការស្តារ ឡើងវិញនៃរូបឆ្លុះរបស់ព្រះដែលបានបាត់បង់។ ពេលដែលយើងបង្ហាញ ពីរូបឆ្លុះរបស់ព្រះម្តងមួយៗទាំងនៅក្នុងគោលបំណង និង ជីវិតរបស់យើងនោះនឹងក្លាយជាផ្លូវដែលនាំ ឱ្យជោគជ័យ។ ព្រះដែលជាព្រះអាទិករដែលបានបង្កើត របស់ទាំងអស់ទ្រង់ចង់បង្ហាញសិរីល្អរបស់ព្រះ ដោយការ បង្ហាញពីរូបឆ្លុះរបស់ទ្រង់។ ក្នុងចំណោមនោះការធ្វើជារូប ឆ្លុះដោយការប្រមូលផ្តុំ ព្រះទ្រង់មានគោលបំណង ដើម្បីបានរីករាយនៅក្នុងលក្ខណៈរបស់ព្រះ និង បានពោរពេញដោយ លក្ខណៈរបស់ទ្រង់នៅក្នុងលោកិយ ទាំងមូល។

ព្រះគម្ពីរបានពន្យល់ពីហេតុផលឱ្យមនុស្សត្រូវតែធ្វើជារូបឆ្លុះរបស់ព្រះ។ ទីមួយនេះជាឧទាហរណ៍ មួយ នៃជីវិត (លោកុប្បត្តិ ១:២៦)។ ការបង្កបង្កើតនៅក្នុងរូបឆ្លុះរបស់ទ្រង់មានន័យថា ការបង្កើត ទាំងនេះហើយជាការ ប្រៀបធៀបនៃកំណាប់ ដែលយ៉ូហានបានមើលឃើញព្រះរាជបុត្រារបស់ព្រះគង់ នៅលើបល្ល័ង្ក: ត្បូងមណីជោតិ សំដៅលើភាពបរិសុទ្ធរបស់ទ្រង់ ត្បូងទទឹមសេចក្តីសុចរិតរបស់ទ្រង់ និង ត្បូងមរកតសេចក្តីស្មោះត្រង់របស់ទ្រង់ (វិវរណៈ ៤:២)។

ទីពីរនោះជាចេស្ដាក្នុងការសំរេចនូវគោលបំណង។ បេសកម្មបី: ការកើត និង ការចំរើនកើងឡើងនៅក្នុង ការកាន់ កាប់លើផែនដី និង អំណាចក្នុងការគ្រប់គ្រងគ្រប់ទាំងរបស់ទាំងអស់ នៅក្នុងលោកុប្បត្តិ ១:២៧ មិនបានចេញមកពីមនុស្សនោះទេ តែបានចេញមកពីលក្ខណៈរបស់ព្រះវិញ។ ដូចនេះយើងគួរតែថែរក្សារូបឆ្លុះ របស់ព្រះនៅក្នុងយើង និង ក្រុមគ្រួសាររបស់យើង សង្គម និង ពិភពលោកដោយសេចក្តីជំនឿ។ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកដើម្បីនឹងធ្វើកិច្ចការនេះនៅក្នុងលោកិយនេះ។ ទីបីនេះជាព្រះពរសំរាប់យើងរាល់គ្នា។ បន្ទាប់ពីទ្រង់បានសំរេចនូវការបង្កើតគ្រប់របស់ទាំងអស់ ព្រះពរដំបូងបង្អស់នោះគឺការដាំរូបឆ្លុះរបស់ទ្រង់ ទៅជាមនុស្ស។ ដូចនេះមនុស្សបានទទួលដំណែងដែលពេញ ដោយអំណាចលើរបស់ទាំងអស់។ ខូចនេះយើងគួរ តែគោរពដល់តំណែងដែល ចេញជាលក្ខណៈ និង ពង្រឹងការនោះយ៉ាងស្មោះត្រង់។

## សរុបសេចក្តីៈ

បន្ទាប់ពីការបង្ករបង្កើតមក តើព្រះអាទិករបានធ្វើអ្វីដើម្បីនិងសរសើរដល់របស់ទាំងអស់ (លោកុប្បត្តិ ១:២៨-៣១)? រហូតមកដល់ពេលនេះពាក្យថា “ល្អប្រពៃ” បានលេចមក៧ដង ប៉ុន្តែនៅទីនេះ “ល្អប្រពៃណាស់” ត្រូវបានដាក់បញ្ចូល។ តើអ្នកដែលទទួលបានបានរៀនពីអ្វី?ទីមួយ គេបានរៀនពី ការបន្ទាបខ្លួន។ ពេលដែល នរណាម្នាក់បានទំនាក់ទំនង ជាមួយធម្មជាតិដ៏អស្ចារ្យ លំហរដ៏ធំក្រៃលែង និង ពិភពលោកដ៏រស់រវើកដែលពេញ ដោយអាថ៌កំបាំង គេនឹងរៀនការបន្ទាបខ្លួនដោយឯកឯង។ លើសពីនេះទៅ ទៀតពេលដែលយើងគិតពីព្រះអាទិករ ជាព្រះដែលបាន បង្កើតពួកគេមកនោះយើងនឹងបន្ទាបខ្លួន។ ទីពីរ យើងរៀនពីការអរព្រះគុណ។ តាមសំណោម របស់យើង ព្រះបានសន្យាថាទ្រង់នឹងផ្តល់នូវរបស់ដែលល្អបំផុតដល់យើង ដូចនេះយើងគួរតែមានការ អរព្រះគុណនិងការ សរសើរដំកើង។ ទីបី យើងបានរៀនពីសេចក្តីស្រលាញ់។ ទ្រង់បានធ្វើការបង្ករបង្កើត បង្ហាញពីសិរីល្អរបស់ព្រះអាទិករ ដោយការបំបែករបស់មួយចំនួនក្នុងការចុះសម្រុងជាមួយគ្នាទៅវិញទៅមក និងការតភ្ជាប់គ្នាដើម្បី នឹងបង្កើតបំណង ហឫទ័យរបស់ព្រះ។

{សំនួរទី2} បន្ទាប់ពីអ្នកបានអានមេរៀនទី២រួចហើយ ដូចឆ្លើយនឹងសំនួរដូចតទៅនេះ។

1. តើនរណាជាពន្លឺនៅក្នុងខ៣នៅក្នុងលោកុប្បត្តិជំពូក១? ចូរប្រៀបធៀបជាជាមួយរបស់ដែលបានបង្កើត នៅ ក្នុងថ្ងៃ ទីបួន។ - នោះជាព្រះគ្រិស្ទដែលជាប្រភពនៃរបស់ទាំងអស់។ ពន្លឺដែលជារបស់ដំបូងបង្អស់ គឺជាព្រះគ្រិស្ទ ដែលជាព្រះគ្រិស្ទដើមមុនពេលចាប់កំណើត។ ពន្លឺនៃរបស់ដែលបានបង្កើតមកជាលើក ទីមួយគឺជាប្រភពនៃគ្រប់ អស់ទាំងពន្លឺ។

2. តើអ្វីទៅជារូបឆ្លុះដ៍ជាក់លាក់របស់ព្រះ? — វាសំដៅទៅលើការប្រមូលផ្តុំលក្ខណៈរបស់ព្រះដោយ វិញ្ញាណ និង ដោយតាមក្រមសីលធម៌។ មនុស្សដែលជារូបឆ្លុះរបស់ព្រះគួរតែបង្ហាញពីសេចក្តី សុចរិតរបស់ព្រះ សេចក្តីមេត្តា ករុណា និង ភាពស្មោះត្រង់របស់ទ្រង់ដែលផ្អែកលើលក្ខណៈរបស់ព្រះ។

3. បន្ទាប់ពីបានអានលោកុប្បត្តិ ១:៦-១៣ ចូរអនុវត្តនូវគោលការណ៍ ពបសឧប ទៅកាន់ពួកគេ។

1) ព្រះ - (៦)ព្រះដែលមានគ្រប់ទាំងអំណាចចេស្តា ជាព្រះដែលអាចបង្កើតគ្រប់ទាំងរបស់ទាំង អស់មក ជារូបរាងដោយព្រះបន្ទូលរបស់ទ្រង់ និង ញែកពួកគេចេញពីគ្នា។ ដោយព្រះបន្ទូលរបស់ទ្រង់ញមួយព្រះឱស្ត ទ្រង់បានបង្កើតភាពរឹងមាំ និង ការបែងចែកទឹកដែលនៅខាងលើ ពីទឹកដែលនៅខាងក្រោម ហើយបានធ្វើឱ្យមានស្រុះគ្នា។ ទ្រង់អាចផ្លាស់ប្តូរចិត្តដែលច្របូកច្របល់របស់ ដោយការផ្តល់នូវ ព្រះបន្ទូលរបស់ទ្រង់ ហើយអាចធ្វើឱ្យមានការស្រុះស្រួលដោយការ បំបែកពួកគេទៅជាការបែងចែកថ្មី។ ដូចនេះខ្ញុំគួរតែផ្តោតគំនិត លើការទទួលយកព្រះបន្ទូលរបស់ព្រះ។

2) អំពើរបាប-គ្មាន

3) ការសន្យា-គ្មាន

4) ការបង្គាប់-(៩) ឱ្យមានដីគោកដុះលេចឡើង

- ដូចដែលដីគោកនិងសមុទ្របានញែកចេញពីគ្នា ហើយត្រូវបានធ្វើឱ្យមានរបៀបរៀបរយដោយការបង្គាប់របស់ ព្រះជាម្ចាស់ ខ្ញុំក៏នឹងមាន របៀបរៀប រយដោយព្រះបន្ទូលដែរ។ ពេលដែលខ្ញុំមានការច្របូកច្របល់ ខ្ញុំគួរតែអនុវត្ត នូវព្រះបន្ទូលរបស់ព្រះ នៅក្នុងជីវិតរបស់ខ្ញុំ និង ក្លាយទៅជាមានសណ្តាប់ធ្នាប់ឡើង។ ព្រះទ្រង់អាចធ្វើបានដោយអស្ចារ្យ

មិនខ្វល់ថាយើងនៅក្នុងសេចក្ដីងងឹតក៏ដោយ។ ចូរយើងធ្វើឱ្យ ខ្លួនមាន សណ្ដាប់ធ្នាប់ឡើង នៅក្នុងនាម របស់ព្រះយេស៊ូវ ដូចដែលយ៉ូស្វេបានបញ្ឈប់ ព្រះអាទិត្យមួយរយៈពេល ដោយការបង្គាប់របស់គាត់។

## មេរៀនទី៣ គោលគំនិតនៃរូបភាព-សួនច្បារអេដែន

1. ចូរគូសរង្វង់នៅជុំវិញបល្ល័ង្គរបស់ព្រះ - សួនច្បារអេដែនជាទីកន្លែងដែលពេញដោយព្រះពរ ប៉ុន្តែថ្ងៃសប្ប័ទ ជាថ្ងៃ នៃព្រះពរ។

2. កាំជណ្ដើរនៅឯភ្នំ និង កាំរស្មីពន្លឺបានចែងចាំងតាមរយៈចំនាំងផ្លាត។-ការប្រកបគ្នារបស់ព្រះ គឺជាគោល បំណងនៃការបង្ករបង្កើត។

3. ព្រះគម្ពីរត្រូវបានមូរទៅផ្នែកខាងឆ្វេង - បណ្ដូលនៃបញ្ញាត្តិទីមួយ ឱ្យស្រឡាញ់តែព្រះតែមួយ ប៉ុណ្ណោះ ហើយឱ្យបានពេលដោយរូបឆ្លុះរបស់ព្រះ។

4. តុដែលស្ថិតនៅខាងឆ្វេង-គ្រួសារដំបូងគឺជាប្រភពស្ថានសួគ៍មួយ។

5. មនុស្សដែលត្រូវបានដេញចេញពីសួនច្បារអេដែនដោយដៃទទួលចុះចាញ់-ការដែលធ្វើតាមចិត្តរបស់ ខ្លួនជាបណ្ដូលនៃអំពើរបាបទាំងអស់។

6. រូបភាពដែលនៅខាងឆ្វេង និង រូបដែលនៅខាងក្រោមបន្តិច-សញ្ញាបីនៃសេចក្ដីសង្គ្រោះ។

1) មនុស្សដែលបានលុតជង្គង់ចុះនៅពេលយកឈើឆ្កាង-ព្រះយេស៊ូវគ្រិស្ទដែលជាពូជរបស់ស្ត្រី។

2) សំលៀកបំពាក់ដែលអ័ដាមនិងអេវ៉ាបានពាក់នោះ - ស្បែករបស់សត្វដែលជាដំណាងអោយ ការសុគត របស់ព្រះគ្រិស្ទ។

3) ដើមឈើដែលមានផលផ្លែនៅខាងឆ្វេង-ដើមឈើសំដៅទៅលើព្រះគ្រិស្ទ ជីវិត។

## មេរៀនទី3 សួនច្បារអេដែន

1. អត្ថបទ: លោកុប្បត្តិ ២:១-៣:២៤
2. ខគន្លិះ: លោកុប្បត្តិ ៣:១៥
3. ការវាយតម្លៃ:

លោកុប្បត្តិ១ផ្តោតលើការបង្កបង្កើតគ្រប់របស់ទាំងអស់ ហើយជំពូកទីពីរផ្តោតលើការបង្កបង្កើត មនុស្ស ។ ជំពូកទីបីបង្ហាញពីការធ្លាក់ចុះ និង ការកាត់ទោសរបស់អ័ដាម និង ការតាំងសញ្ញានៃព្រះគុណ បានលេច មកជាលើកទីមួយ។
នៅក្នុងមេរៀននេះពន្យល់ពីរបៀបដែលរូបឆ្លុះរបស់ព្រះបានចាប់ផ្តើមឡើង អំពើរបាបបានបំផ្លាញអ្វីខ្លះ ហើយវានឹងត្រូវស្តារឡើងវិញជាយ៉ាងណា។

4. ការពន្យល់:

នៅក្នុងលោកុប្បត្តិជំពូកពីរ យើងបានឃើញពីការបង្កបង្កើតនៃថ្ងៃឈប់សំរាក ការបង្កើតសួនច្បារអេដែន បញ្ញាត្តិ ដំបូង និង គ្រួសារដំបូងដែលបានចេញមកពីការបង្កើតរបស់អេវ៉ា។

1. ថ្ងៃដែលព្រះបានប្រទានពរ (លោកុប្បត្តិ ២:១-៣)

ដើម្បីដាក់ច្បាប់នៅក្នុងថ្ងៃសប្ប័ទជាថ្ងៃនៃព្រះពរ ដែលមានគោលបំណងដើម្បីរក្សាថ្ងៃនោះជាថ្ងៃនៃព្រះ ពរដោយ បង្ហាញពីឧទាហរណ៍របស់ព្រះ។ ពេលដែលមនុស្សធ្វើល្មើសនឹងច្បាប់ គេត្រូវតែគេចចេញពីសេចក្តីងងឹត ហើយឱ្យ បានរីករាយនៅក្នុងការឈប់សំរាកដ៏ពិតវិញ។ មិនធ្វើកិច្ចការផ្ទាល់ខ្លួន ការបង្កបង្កើតសារឡើងវិញ ធ្វើការហើយ គោរពថ្ងៃឈប់សំរាក ហើយរក្សាថ្ងៃនោះជាថ្ងៃរបស់ព្រះយេហូវ៉ា (អេសាយ ៥៨:១៣)។ លើសពីនេះទៅទៀត ថ្ងៃនោះជាថ្ងៃដែលយើងត្រូវប្រមូលផ្តុំគ្នានៅក្នុងក្រុមជំនុំ។ កិច្ចការដែលបានធ្វើរួចហើយនៅ ក្នុងរយៈពេលប្រាំមួយ ថ្ងៃ នោះមិនត្រូវធ្វើឡើយ ហើយត្រូវបើកទ្វារចិត្ត

ដោយការអរព្រះគុណដល់ព្រះនៅ ក្នុងការចងចាំពីការបង្កបង្កើត និងការបង្កើតឡើងសារជាថ្មី។ (លោកកាល់វីន)“គ្រានោះឯងនឹងបានចិត្ត រីករាយក្នុងព្រះយេហូវ៉ា ហើយអញនឹងបញ្ជិះឯងនៅលើទីខ្ពស់នៃផែនដី ហើយនឹងចញ្ចឹម ឯងដោយមរតករបស់យ៉ាកុប ជាឰយុកោឯង ដ្បិតព្រះឱស្ឋនៃ ព្រះយេហូវ៉ាបានចេញវាចាហើយ” (អេសាយ ៥៨:១៤)។

តើអ្វីទៅជាគោលបំណងក្នុងការបង្កើតថ្ងៃសប្ប័ទ? ទីមួយ នេះជាថ្ងៃអោយបានចងចាំពីការបង្កបង្កើតរបស់ព្រះ។ ពាក្យថា “ថ្ងៃទីប្រាំពីរ” បានលេចមកប្រាំពីរដងដែលដាច់ចេញពីប្រាំមួយថ្ងៃទៀតដែលគ្រាន់តែជាថ្ងៃដែលគ្រាន់តែ សំគាល់សារឡើងវិញបីដងប៉ុណ្ណោះ។ ព្រះបានបំពេញគ្រប់ទាំងទីលំហរ និង ផែនដីទាំងមូលដោយសេចក្តីស្រលាញ់ និង ភាពស្មោះត្រង់របស់ទ្រង់។ ដូចដែលព្រះបានដាក់គ្រប់ការទាំងអស់នៅកន្លែងដែលសមគួរ ហើយក៏រៀបចំគ្រប់ ទាំងព្រះគុណដ៏ប្រសើរបំផុតសំរាប់កការប្រោសលោះរបស់គេ។ ទីពីរ ការនេះត្រូវបាន ផ្តោតទៅលើការឈប់សំរាក ខាងឯព្រលឹងវិញ្ញាណ។ បញ្ហានៅក្នុងសភាពជាវិញ្ញាណនៃរាស្ត្ររបស់ព្រះអម្ចាស់ នៅក្នុងថ្ងៃធ្វើការទាំងប្រាំមួយថ្ងៃ នឹងត្រូវបានដោះស្រាយដោយការផ្តោតគំនិតនៅលើការថ្វាយបង្គំ ដែលជាទំនាក់ទំនងជាមួយនិងព្រះ។ នៅក្នុងថ្ងៃ សប្ប័ទ ការឈប់សំរាកគឺសំខាន់ជាងថ្ងៃនោះផង។

លោកម៉ូសេប្រើជំពូក២ដើម្បីបង្ហាញពីរបៀបដែលព្រះបង្កើតមនុស្សដែលជាចំនុចកំពូលនៃការបង្កបង្កើត។ ទីមួយ ព្រះទ្រង់ត្រូវការមនុស្ស។ ចំនុចនេះបានបញ្ជាក់ពីការនេះ “ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតឱ្យចំ នឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី” (១:២៧)-ធ្វើឱ្យយើង បានគិតពីការការបង្កបង្កើត ដែលមានមនុស្សជាកណ្តាល។ ព្រះទ្រង់ត្រូវការអ្នកគ្រប់គ្រងដែលថែរក្សារ គ្រប់អស់របស់ដែលបានបង្កើតមកដើម្បីឱ្យបាន ថ្វាយសិរីល្អដល់ទ្រង់។ ទីពីរ មនុស្សជារូបកាយដែលគ្មាន ប្រភព។ ពេលដែលព្រះបានបង្កើតមនុស្សចេញពីធូលីដី ទ្រង់បានបញ្ជាក់ថាគេមិនមានអ្វីទាំងអស់នៅក្នុងវត្តមានរបស់គេ ដែលគេជារូបកាយដែលត្រូវការពឹងផ្អែក ដោយមិនមានឯករាជ្យឡើយ។ ការសារភាពរបស់ សាវ័កប៉ូលបានបង្រៀនដល់យើង ពីប្រភពនៃការបង្កបង្កើតនៅក្នុងភាពស្មៀម ស្ងាត់: “ប៉ុន្តែខ្ញុំបានជាយ៉ាងណា នោះគឺដោយដោយព្រះគុណនៃព្រះទេ ហើយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំ នោះមិនមែនជាអសារឥតការ ឡើយ ដ្បិតខ្ញុំបានខំធ្វើការលើសជាងអ្នកទាំងនោះសន្ធឹកណាស់ ប៉ុន្តែមិនមែនជាខ្ញុំ គឺជាព្រះគុណនៃព្រះដែល សណ្ឋិតនៅនឹងខ្ញុំវិញ” (១កូរិនថូស្ស១៥:១០) ។ ដូចនេះការដែលធ្វើអ្វីដោយចិត្តឯង

ត្រូវបានទេរទៅរក ផ្លូវនៃសេចក្ដីហិនវិនាស។ ទីបី គេជាវិញ្ញាណដែលមានជីវិតរស់នៅ។ ព្រះបានដាក់ខ្យល់ដង្ហើមជីវិតនៅក្នុង រន្ធច្រមុះរបស់គេ។ ព្រះវិញ្ញាណបរិសុទ្ធដែលបានរេរា នៅលើផ្ទៃនៃ សេចក្ដីងងឹត ភាពទទេ និង ភាពច្របូកច្របល់ បានគ្របដណ្ដប់គេដោយសេចក្ដីស្រឡាញ់ដែលមិនអាច ដកចេញបានសំរាប់របស់ដែលទ្រង់បានបង្កើតមក។ ដូចជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែលបាន បង្ហាញពីការបង្កបង្កើតនៃរបស់គ្រប់ទាំងអស់ (លោកុប្បត្តិ ១:២) ហើយ ក៏ទៅកាន់សកម្មភាពនៃការសរសេរ នៅក្នុងព្រះគម្ពីរផងដែរ (២ធីម៉ូថេ ៣:១៦) ការបង្កើតមនុស្ស បានដើរតាមបន្ទាត់ ដូចគ្នានៅក្នុងរបៀបរៀបរយដើម្បីនិងសង្កត់ធ្ងន់លើការទំនាក់ទំនងតែមួយ នៃព្រះវិញ្ញាណ បរិសុទ្ធដែលអាចធ្វើបាន។ សេចក្ដីស្រឡាញ់របស់ព្រះទៅកាន់មនុស្សគួរតែបានសង្កត់ធ្ងន់លើដោយការបង្ករ បង្កើតនៃសួនច្បារអេដែន។

2. ការប្រកបនៃសួនច្បារអេដែន (លោកុប្បត្តិ ២:៤-១៤)

ដោយពេលថ្ងៃសប្ប័ទជាថ្ងៃដែលមានពរពិត ដោយកន្លែងជាសួនច្បារអេដែន។ គោលបំណងរបស់ព្រះក្នុងការ បង្កើត សួនច្បារអេដែននោះ គឺដើម្បីនឹងដាក់អ្នកគ្រប់គ្រងម្នាក់ដែលគួរតែថែរក្សាគ្រប់ទាំងរបស់ទាំងអស់ ជាទីកណ្ដាលនៃ គ្រប់ទាំងអស់។ ដោយអត្តន័យដូចនេះ សួនច្បារអេដែនជាការចំលងមួយនៃបល្លង្គរបស់ព្រះ និង ព្រះវិហាររបស់ទ្រង់ និង ទីបរិសុទ្ធរបស់ទ្រង់ដែលបានពេញដោយព្រះវត្តមានរបស់ព្រះ (៤-៨)។

លើសពីនេះទៅទៀតត្រូវបានបង្កើតមកសំរាប់ការប្រកបជាមួយនឹងព្រះ។ នៅក្នុង ខ៨បានបង្ហាញថាព្រះ ទ្រង់ជា ម្ចាស់ ហើយមនុស្សគ្រាន់តែជាភ្ញៀវម្នាក់ប៉ុណ្ណោះ។ អេម៉ាញ៉ូអែលមានន័យថា នៅជាមួយនឹងព្រះ ហើយក៏ជា ជីវិតអស់កល្ប ជានិច្ចដែលស្គាល់ព្រះដែលអាចពិសោធបាន (យ៉ូហាន ១៧:៣)។ ជាទូទៅទីកន្លែងសំរាប់ប្រកបគ្នា នឹងក្លាយទៅជា សួនច្បារនៃក្ដីអំណរអរសប្បាយ (អេសេគាល ២៨:១៤)។ ទោះជាវាសំខាន់យ៉ាងណាក៏ដោយ ដែលសួនច្បារអេដែនមានបរិស្ថានស្អាត នាំឱ្យមានអំណរអរសប្បាយ (អេសេគាល ២៨:១៣) ដែលសំខាន់ ជាងនោះទៅទៀតការ ដែលទទួលបានភាពពេញលេញនៃព្រះគុណ និង សេចក្ដីពិតរបស់ព្រះពីការប្រកបជាមួយនឹងព្រះ។ ទោះជាក្រុមគ្រួសាររបស់យើងបានធ្លាក់ទៅក្នុងសេចក្ដីងងឹត យ៉ាងណាក៏ដោយ ប្រសិនបើយើងបានស្ដារឡើងវិញ

ដោយការអធិស្ឋាន និង ព្រះបន្ទូល នោះយើងនឹងអាចមាន អំណារនូវអំណារដ៏ពេញលេញរបស់សួនអេដែន។
ហើយតើអ្វីទៅជាអត្ថន័យរបស់ទន្លេទាំងបួនបានផ្តល់ដល់យើង: ទន្លេពិសុន ទន្លេគីហុន ទន្លេហ៊ីដេកែល និង ទន្លេអ៊ើ ប្រាត ដែលបានចេញមកពីភ្នំដែលបរិសុទ្ធរបស់ព្រះ ហើយបានពេញដោយសិរីល្អរបស់សេខានី? ដំបូងវាបង្ហាញពី សេចក្តីសង្គ្រោះរបស់ព្រះគ្រិស្ទ។ ដូចដែលទន្លេបានហូរចេញពីសួនច្បារអេដែន (១០) មានតែព្រះគ្រិស្ទប៉ុណ្ណោះ ដែលជាសេចក្តីសង្គ្រោះ ហើយទ្រង់ជាអ្នកសំរេចបំពេញសេចក្តីសង្គ្រោះ (យ៉ូហាន ៤:១៤ ១៤:៦)។ ទីពីរ វាបានកំរិតទន្លេរនៃជីវិតរបស់ព្រះវិញ្ញាណបរិសុទ្ធ (១៦)។ វាបានបង្ហាញ ថាអ្នកណាដែលជឿដល់ព្រះគ្រិស្ទនិងមានទឹករស់ ហូរចេញមកដោយចង្អុលទៅកាន់ប្រភពទឹកដ៏ពេញបរិបូររបស់ ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងចិត្តរបស់ពួកគេ ព្រោះទ្រង់ ជាវិញ្ញាណរបស់ព្រះគ្រិស្ទ (យ៉ូហាន ៧:៣៨-៣៩)។ នេះជាសញ្ញានៃជីវិត (វិវរណៈ ២១:១-២)។ ទីបី វាបានបង្ហាញពីការរីកចំរើននៃភាពរីកដុះដាលដែល បានធ្វើជាទម្រង់នៅក្នុងកណ្តាលបល្លង្ករបស់ព្រះទៅតាមវប្បធម៌នៅ ក្នុងព្រះគម្ពីរ។ ដូចនេះយើងត្រូវបង្កើត ផលផ្លែតាមសេចក្តីស្មោះត្រង់នៅក្នុងការបច្ចុប្បន្ននេះ ដោយសារវាទាក់ទង និងព្រះពរនាពេលបច្ចុប្បន្ននេះ ហើយនិងរង្វាន់មកពីស្ថានសួគ៌ផងដែរ។ (ម៉ាថាយ ២៥:១៤-៣០)
បន្ទាប់ពីថ្ងៃនោះមកព្រះទ្រង់បានបង្កើតមនុស្សស្រី។ ហេតុអ្វីបានជាព្រះបង្កើតមនុស្សស្រីដែលមានរូបឆ្លុះរបស់ ព្រះដូចជាអ័ដាមមានដែរ? ទីមួយ ទ្រង់មិនសប់ព្រះហឫទ័យជាមួយនឹងភាពឯកោរបស់គេឡើយ។ (១៨)ដូច ដែលអង្គបីនៅក្នុងមួយ អ័ដាម-ជាអ្នកដែលត្រូវបានបង្កើតមកនៅក្នុងរូបឆ្លុះរបស់ព្រះ-ក៏ត្រូវការរៀនពីការរួបរួម ដែរ។ ភាពតែឯកឯងជាមួយនឹងបុគ្គលពីរប្តី និង ប្រពន្ធបង្ហាញការយ៉ាងប្រសើរមកដល់យើង។ (១៨) ទីពីរ វាបាន បង្រៀនពីសារៈសំខាន់នៃការរួបរួមតាមរយៈប្តីប្រពន្ធឱ្យជួយគ្នា (២០-២២)។ រូបឆ្លុះរបស់ព្រះត្រូវ បានចាប់ផ្តើម ដោយលក្ខណៈសម្បត្តិរបស់មនុស្សម្នាក់ ហើយត្រូវបានបញ្ជាក់តាមរយៈការរួបរួមជាមួយ នឹងអ្នកជិតខាងខ្លួន។ សេចក្តីសង្គ្រោះបំបែកបំបាក់ការរួបរួមជាមួយនឹងអំពើរបាប ប៉ុន្តែបង្កើតការរួបរួម ជាមួយនឹងព្រះ។ នេះជាឧទាហរណ៍ ដែលក្រុមជំនុំត្រូវតែរៀនដើម្បីរួបរួមរវាងមនុស្សស្រី និង មនុស្សប្រុស។ ទីបី វាបានបង្រៀនពីសេចក្តីស្រឡាញ់របស់ ព្រះ។ អ័ដាមបានមើលទៅអេវ៉ា ហើយបានសារភាពថា "អ័ដាមក៏ថានេះហើយជាឆ្អឹងពីឆ្អឹងអញ ជាសាច់ពីសាច់អញ នឹងត្រូវហៅថា (ស្ត្រី)ពីព្រោះបានយក

ចេញពីបុរសមក។” (២៣) វាជាការសារភាពនៃសេចក្តីស្រលាញ់ដ៏ពិត។ ការជាក់ស្តែង ដែលព្រះបានបង្កើតអេវ៉ាចេញពីរបស់ដែល ល្អលើសគេរបស់អ័ដាមដែលចង្អុលទៅកាន់ សេចក្តីស្រឡាញ់របស់ព្រះ។ សេចក្តីស្រឡាញ់របស់ព្រះនៅក្នុង ការបង្កបង្កើតត្រូវបាន បង្ហាញមកយ៉ាងខ្លាំងក្លានៅក្នុងការប្រោសលោះ ដែលព្រះបានចាត់ព្រះរាជបុត្រាតែមួយ របស់ព្រះអង្គមកលើផែនដីនេះ។

3. បញ្ញាត្តិទីមួយ (លោកុប្បត្តិ ២:១៥-១៧)

ដើម្បីនឹងរក្សាបរិស្ថានដែលពេញដោយព្រះពរបន្ត ហើយមានពិភពលោកដែល ប្រសើរ ឱ្យមនុស្សមាន ជីវិតអស់កល្ប ជានិច្ច ព្រះបានប្រទានបញ្ញាត្តិដល់ពួកគេជាដំបូង (១៦-១៧)។ បញ្ញាត្តិទាំងនេះដូចជា វិតាមីនគ្រប់ប្រភេទ ដែលរាប់ បញ្ចូលទាំងច្បាប់ និង ការបង្គាប់។ តើបញ្ញាត្តិទាំងនោះជាអ្វី? ទីមួយ ជាបញ្ញាត្តិ ដែលឱ្យស្រលាញ់តែព្រះ ប៉ុណ្ណោះ។ ព្រះអម្ចាស់មានបន្ទូលថា “តាំងពីដើមមក អ្នករាល់គ្នាមិនបានសូម អ្វីដោយនៅ ឈ្មោះខ្ញុំទេ ឥឡូវចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឱ្យសេចក្តីអំណររបស់អ្នករាល់ គ្នា បានពោរ ពេញពិត” (យ៉ូហាន ១៦:២៤)។ លៃកាសាវ័កប៉ូល ក៏បានទាញយកក្រុមជំនុំអេ ភេសូទៅកាន់ព្រះ និង ព្រះបន្ទូលដែលពេញដោយព្រះគុណ (កិច្ចការ ២០:៣២) ដោយសារ តែគាត់បានដឹងប្រាកដថាការដែល ស្រលាញ់ព្រះបន្ទូល គឺជាការស្រលាញ់ព្រះជាម្ចាស់។ ទីពីរ បញ្ញាត្តិនេះជា បញ្ញាត្តិដែលទាមទារការស្តាប់ បង្គាប់ទាំងស្រុង។ កំរិតនៃការស្តាប់ បង្គាប់ត្រូវពឹងលើគោលបំណងនៃការស្តាប់បង្គាប់ នៅពេលដែលព្រះអាទិករ បនាប្រទាន បញ្ញាត្តិមកយើង យើងត្រូវតែឆ្លើយតបដោយការស្តាប់បង្គាប់ទាំងស្រុង។ លើសពីនេះទៅ ទៀត បញ្ញាតិត្រូវបានសន្មត់ថាជាដើមឈើនៃជីវិត ដែលបើកសំដែងពីរបៀបដើម្បីទទួល បានព្រះពរ ដោយជ្រើសរើស ព្រះ និង បំណងព្រះហឫទ័យរបស់ទ្រង់។
ទោះបីជាអ័ដាមបានបាត់បង់ឱកាសយ៉ាងក្រៀមក្រំ ហើយបានធ្លាក់ចុះទៅក្នុងដី ដោយគ្មាន សង្ឃឹមអ្វីទាំងអស់។ អ័ដាមទីពីរបានចាប់ផ្តើមការនោះ។ យើងជាអ្នកដែលនៅជាប់នឹង ដំណឹងល្អនឹងបានរីករាយជាមួយនឹងព្រះពរនេះ។

4. ក្រុមគ្រួសារដំបូង (លោកុប្បត្តិ ២:១៨-២៥)

នៅលើផែនដីព្រះបានបង្កើតវិជ្ជាស្ថានពីរៈក្រុមជំនុំ និង ក្រុមគ្រួសារ។ ហេតុអ្វីបានជាព្រះបានផ្តល់នូវប្រព័ន្ធ នៃគូស្វាមី ជាមាត្រាមួយ? ទីមួយ មនុស្សត្រូវរៀនពីសេចក្តីស្រលាញ់ និង ការស្តាប់បង្គាប់បែបនោះទៅកាន់ព្រះ តាមរយៈជីវិត ជាប្តីប្រពន្ធ (អេភេសូ ៥:២២-២៥)។ ព្រះបានប្រទានប្រពន្ធទៅដល់ប្តីសំរាប់ធ្វើជាអ្នកជំនួយ ហើយប្តីធ្វើជាក្បាលជា អ្នកដឹកនាំនៅលើប្រពន្ធនៅក្នុងសេចក្តីត្រូវការរបស់នាងចំពោះប្តី និង ការដឹកនាំរបស់ ប្តីទៅលើប្រពន្ធរបស់ខ្លួន។ (១៦)

នេះជាព្រះពរដែលព្រះបានផ្តល់មក។ ផ្ទះជាបរិស្ថានមួយដែលបានរៀបចំទុកជាមុនយ៉ាងជាក់លាក់ សំរាប់រៀនពី សេចក្តី ស្រលាញ់ និង ការស្តាប់បង្គាប់ដល់ជីវិតស្ថានសួគ៌នាពេលអនាគត។ ទីពីរ តាមការរួបរួមរបស់ប្តីប្រពន្ធ ពួកគេអាចរៀន ពីការរួបរួមគ្នារវាងព្រះគ្រិស្ទ និង ក្រុមជំនុំ។ “ដោយហេតុនោះបានជាមនុស្សប្រុស នឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅ ជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែមួយសុទ្ធ” (២៤)។ ពេលដែលយើងមានការទាស់ទែង រវាងប្តីប្រពន្ធ ប្តីប្រពន្ធអាចមានសង្ឃឹមដោយការបែ ត្រឡប់មកការស្រលាញ់ និង ការស្តាប់បង្គាប់របស់ប្តីប្រពន្ធដំបូងវិញ។ លោកម៉ូសេបានបង្ហាញពីការ បង្កបង្កើតសារជាថ្មី ដែលបានលាក់ ទុកនៅក្នុងស្រមោលនៃការបង្កបង្កើតនៅក្នុងជំពូកបី។ គាត់បានរៀបរាប់ ពីរូបមួយចំនួនអំពរបៀបដែលមនុស្សបាន បាត់បង់រូបឆ្លុះរបស់ព្រះ អ្វីដែលជាលទ្ធផលដែលបានដើរ តាមពួកគេ និង ពីរបៀបដែលមានការស្តារឡើងវិញ នៃរូបឆ្លុះរបស់ព្រះ។

5. អំពើរបាបដំបូង (លោកុប្បត្តិ ៣:១-៧)

តើអំពើបាបបានចូលមកឯមនុស្សដោយរបៀបណា? មានដំណាក់កាលបីយ៉ាង។ ទីមួយ អ្នកល្បួង ដែលជាសត្វពស់ បានចាប់ផ្តើមដោយសំនួរដែលនាំឱ្យពួកគេឆ្ងល់។ “ឯពស់ជាសត្វមានឧបាយកលលើសជាង អស់ទាំងសត្វព្រៃ ដែលព្រះ យេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើព្រះមានបន្ទូល ហាមមិនឱ្យ អ្នកបរិភោគផ្លែឈើណានៅ ក្នុងសួនច្បារមែនឬ” (១)? វាជាសំនួរអវិជ្ជមានមួយ ដែលបញ្ចុះបញ្ចូល ឱ្យមានការរអ្ងូរទាំ និង ការអាក់អន់ចិត្ត។ ទោះបីគ្រប់ទាំងសំនួរវិជ្ជមានមិនមែនជាការមិនជឿក៏

ដោយ គ្រប់ទាំងការមិនជឿបានលេចឡើងមកជាអវិជ្ជមាន។ ការសង្ស័យជាអាវុធដ៏សំខាន់របស់សាតាំង ។ ជំហាន បន្ទាប់ទៀត សាតាំងបានវាយប្រហារពួកគេដោយការកុហក។ "រួចពាស់កនិយាយទៅស្ត្រីថា អ្នកមិនស្លាប់ជា ពិតមែន" (៤)។ អារក្សបានប្រឈមមុខនឹងពួកគេឱ្យឈរទាស់នឹង បញ្ញាត្តិទីមួយ ។ វាបានល្បួងពួកគេ ដោយនិយាយ ពាក្យផ្អែមល្ហែមដើម្បីបំបែពួកគេចេញពីទំនាក់ទំនងជាមួយនឹងព្រះ ហើយឱ្យ បានជ្រើសរើសតាមវាដោយអេវ៉ា ផ្ទាល់។ ជាចុងក្រោយអេវ៉ាបានជ្រើសរើសយកការធ្វើតាមចិត្តខ្លួនឯង និង បានបរិភោគ ផ្លែឈើ ហើយបានយក ទៅឱ្យប្តីចូលរួមក្នុងការនោះដែរ។

ដំណាក់កាលនៃការប្រព្រឹត្តអំពើបាបដើរតាមយើងនៅក្នុងរបៀបដូចគ្នា។ ផ្លូវតែមួយគត់ដែលអាចយក ឈ្នះលើសេច ក្តី ល្បួងដូច្នេះបាន គឺជាការនៅជាប់នឹងព្រះបន្ទូលរបស់ព្រះ។ តើអំពើរបាបបានចាប់ផ្តើមដំបូង ដោយរបៀបណា ហើយ អ្វីទៅជាលទ្ធផលដែលវាបាននាំមកឱ្យពួកគេ? ទីមួយ វាបានចាប់ផ្តើមដោយ ការល្បួងរបស់សាតាំង (១)។ សាតាំងដែលបានបាត់បង់ជំណែងរបស់ខ្លួន ហើយបានក្លាយជាពុករលួយ-បានធ្វើឱ្យពួកគេបានបោះបង់ចោលទំនាក់ទំនងរបស់ ពួកគេជាមួយនឹងព្រះ។ វាបានមកឯនាងអេវ៉ាដែលខ្សោយ។ ទីពីរ វាបាននាំយកនូវបញ្ហានៅក្នុងការស្តាប់ព្រះបន្ទូល របស់ព្រះ (១-៣)។ សាតាំងបានវាយប្រហារនាងដោយសំណួរ អវិជ្ជមាន ហើយធ្វើឱ្យនាងមានការសង្ស័យនៅ ក្នុងការស្តាប់ ព្រះបន្ទូលរបស់ព្រះ។ ការដែលនៅជាប់នឹង ព្រះបន្ទូលរបស់ព្រះនោះជាព្រះពរ។ ទីបីគោលបំណងរបស់ សាតាំងគឺធ្វើ យ៉ាងណាឱ្យមនុស្សបាន ធ្លាក់ចុះធ្វើតាមចិត្តរបស់ខ្លួន (៦)។ នាងបានជ្រើសរើសយកផ្លែឈើ ដែលបាន ហាមឃាត់មិន ឱ្យបរិភោគ ទៅតាមចេតនានៃចិត្តដ៏ពុករលួយរបស់នាង។ ទង្វើដ៏តូចនេះបាននាំឱ្យ មនុស្សទាំងអស់បាន ធ្លាក់ទៅក្នុងសេចក្តីស្លាប់។

សេចក្តីស្លាប់ដោយគ្មានសេចក្តីស្រឡាញ់មកពីព្រះ ដោយសារតែព្រះដែល បានខិតមកជិតមនុស្សមានបាប នោះជាអ្នក កាត់ទោស។ ទីពីរ ពួកគេបានគេចចេញពីព្រះភ័ក្ររបស់ព្រះ។ (៨-១០) ជាសកម្មភាពលាក់នូវ កេរ្តិ៍ខ្មាស់របស់គេនៅ ក្រោមស្លឹកឈើ ដែលនឹងត្រូវបានដកចេញដោយការលាក់ខ្លួនរបស់ពួកគេខាងក្រោយ ភ្នំខ្ពស់ៗ (វិវរណៈ ៦:១៦)។ អ្នក ដែលដើរតាមអំពើទុច្ចរិតរត់គេចចេញពីព្រះភ័ក្ររបស់ព្រះ ហើយរស់នៅក្នុង សេចក្តីងងឹត។ ទីបី ពួកគេត្រូវបាន គ្រប់គ្រង ដោយបន្ទុកនៃសេចក្តីកំហុស។ ចំពោះសំនួររបស់ព្រះ "ហេតុអ្វីបានជាឯងពួន?" អ័ដាមមិនមានទំនួលខុស ត្រូវឡើយ ប៉ុន្តែ បានចង្អុលទៅកាន់សេចក្តីល្បួង

របស់អេវ៉ា ដោយសារតែមនសិការរបស់គាត់ត្រូវបានគ្រប់គ្រងដោយ បន្ទុកមួយចំនួន។ យើង ត្រូវតែសរសើរដំកើង ព្រះអម្ចាស់ដោយសារសេចក្តីសប្បុរសរបស់ព្រះគ្រិស្ទ។

2. ឯងនៅឯណា អ័ដាម? (លោកុប្បត្តិ ៣:៨-១៣)

នេះមិនមែនជាទីបញ្ចប់នោះទេ ព្រះដែលបានបង្កើតពួកគេមកបានយាងមកឯពួកគេ ដោយសេចក្តីសុចរិត និង សេចក្តីស្រឡាញ់? ទីមួយ តើសេចក្តីស្រឡាញ់របស់ព្រះត្រូវបាន បង្ហាញមកដោយរបៀបណា? "រួមមកបានឮសំលេងរបស់ព្រះយេហូវ៉ាដ៏ ជាព្រះ ដែល ទ្រង់ ក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ នោះអ័ដាមនិងប្រពន្ធគាត់ ក៏ពួននិងព្រះយេហូវ៉ា ដ៏ជាព្រះ នៅកណ្តាលដើមឈើក្នុងសួនច្បារ" (៨)។ វាបានចង្អុលប្រាប់ថាព្រះយេហូវ៉ាមិន បានដើរនៅក្នុងសួន ច្បារដោយស្ងាត់ៗ នោះទេ ប៉ុន្តែដូចជាស្នូរបស់ស៊ីរ៉ែន។ ព្រះបានយាងមកឯ ពួកគេក្នុង បែបជាព្រះដែលសុចរិត និង ជាព្រះដែលកាត់ទោស ដូច្នេះបានជាពួកគេបាន លាក់ខ្លួនជាមួយស្លឹកឈើ ដោយមាន ការផិតភ័យយ៉ាងខ្លាំង។ គ្រប់ទាំងអំពើបាបទាំងអស់ នឹងឈរនៅរឹងម៉ាំចំពោះបល្ល័ង្គកាត់ទោសរបស់ព្រះ។ ប៉ុន្តែទោះបីជាទ្រង់ជាព្រះដែល គួរឱ្យភ័យក្លាចក៏ដោយ ទ្រង់ក៏ជា ព្រះដែលពេញដោយព្រះគុណនិងសេចក្តីមេត្តាករុណា ដោយ ព្រះគុណនិងសេចក្តី ស្រឡាញ់។

ព្រះបានប្រទានឱកាសក្នុងការអត់ទោសមកដល់មនុស្ស (៩)។ សំណួរ "ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅ រកអ័ដាមដោយ បន្ទូលថា ឯនៅឯណា?" នោះជាឧកាសនៅក្នុងការអត់ទោស។ ប៉ុន្តែពួកគេបានឆ្លើយតម ដោយការគេចចេញពីទំនួល ខុសត្រូវ (១២-១៣)។ អ្នកដែលមានទំនួលខុសត្រូវហើយស្វែងរកការអត់ទោស អាចទទួលបាននូវព្រះគុណមកពី ព្រះ ដោយសារនេះជាការប្រែចិត្តពិតប្រាកដ (កិច្ចការ ២:២១)។ ព្រះបានកាត់ទោស អំពើបាបរបស់ពួកគេ។ ទីមួយ ព្រះបានដាក់បណ្តាសារដល់សត្វពស់ដោយរស់ នៅលើផែនដី ខុសពីសត្វដទៃទៀត ដោយសារតែវាបានធ្វើជាអ្នកបំរើរបស់ សាតាំង ទោះជាវាត្រូវបាន បង្កើត មកយ៉ាងល្អដោយសារព្រះក៏ដោយ។ នេះបង្ហាញពីការប្រកាសនៃការបំផ្លាញដល់ សាតាំង (១៥)។ សាតាំង និង កិច្ចការរបស់វាត្រូវបានកំទេចចោលដោយការសុគតរបស់ ព្រះគ្រិស្ទ។ ទីពីរព្រះ បានបន្ថែមការឈឺចាប់ដល់អេវ៉ា នៅពេលផ្តល់កំណើត (១៦)។ ទោះជាកំណើតដោយផ្ទាល់ជាព្រះពរ តែការឈឺ ចាប់បានដាស់តឿនគេពីអំពើរ បាបដែលគេបានប្រព្រឹត្តិ ទោះបីជា ព្រះបានអនុញ្ញាត្តឱ្យគេត្រូវបានធ្វើកិច្ចការដើម ដំបូងឡើងដោយការឈឺចាប់។ ទីបី ព្រះបានផ្តល់ឱ្យមានការនឿយ ហត់នៅក្នុងការងាររបស់អ័ដាម (១៧-

១៩)។ កិច្ចការនោះឯងជាព្រះពរ តែព្រះបានបន្ថែមការបែកញើស និង ការឈឺចាប់ ជាចុងក្រោយទ្រង់បាន កាត់ដោយ សេចក្តីស្លាប់។ ប៉ុន្តែសេចក្តីស្លាប់នេះត្រូវបានកាន់កាប់ដោយសេចក្តី ស្លាប់របស់ព្រះគ្រិស្ទ។ យើងត្រូវតែលើក ដំកើងការសុគត របស់ព្រះគ្រិស្ទ ដែលជាសេចក្តីស្លាប់នៃអស់ទាំងសេចក្តី ស្លាប់។

1. ដំណឹងល្អពីសេចក្តីសង្គ្រោះដំបូង (លោកុប្បត្តិ ៣:១៤-១៩)

ជាទូទៅព្រះគម្ពីរលោកុប្បត្តិ ៣:១៥ ត្រូវបានហៅថាជាដំណឹងល្អដើម ដោយសារវាបង្ហាញពីការ បំផ្លាញ ដល់សាតាំង និង អំពើរបាប និង វិធីសាស្រ្តនៃការសង្គ្រោះឱ្យរួចពីអំពើរបាប។ វាបង្រៀនលក្ខណៈនៃដំណឹង ល្អមកដល់យើង នៅក្នុង ឥរិយាបថមួយដែលជាក់លាក់។ ទីមួយការសង្គ្រោះជាការបង្កើតភាពជាសត្រូវ ទាស់នឹងសាតាំង ហើយដើម្បីនឹងរួបរួមជាមួយនឹងព្រះ។ “អញនឹងធ្វើឱ្យឯងហើយនឹងស្ត្រី គឺទាំងពូជឯងនិងពូជនាង មានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាល ឯង ហើយឯងនឹងចឹកកែងជើងគេ” (៣:១៥)។ ព្រះបានធ្វើឱ្យយើង ក្លាយ ជាសត្រូវនឹងសាតាំង ហើយបានបង្រួប បង្រួមយើងជាមួយនឹងព្រះ (យ៉ូហាន ៥:២៤)។ ទីពីរ សេចក្តីសង្គ្រោះនោះត្រូវ បានសំរេចបំពេញដោយ ពូជរបស់ស្ត្រី ដែលជាព្រះយេស៊ូវគ្រិស្ទ។ ដូចនេះបានជាសាវ័ក ប៉ូលបានបញ្ជាក់ថា “ព្រះគ្រិស្ទដែលប្រសូតមកដោយស្ត្រី” (កាឡាទី ៤:៤)។ ទីបី មានតែព្រះប៉ុណ្ណោះ ជាអ្នកដែលសំរេចនូវសេចក្តីសង្គ្រោះ ដោយមិនចាំបាច់ពិភាក្សារជាមួយយើង ដោយ សារទ្រង់បានបង្ហាញឆន្ទៈ របស់ទ្រង់ផ្ទាល់ដោយមានបន្ទូលថា “មាន សេចក្តីខ្មាំងនឹងគ្នា”។

តើព្រះបានធ្វើអ្វីដើម្បីបង្ហាញសេចក្តីសុចរិតរបស់ទ្រង់? ទីមួយ អ្នកដែលដឹកនាំឱ្យធ្វើអំពើរបាប និង អ្នកបំរើត្រូវបាន កាត់ទោស។ ព្រះទ្រង់បានអនុញ្ញាតការតាំងសញ្ញានៃការចុះកិច្ចសន្យាជាមួយអ័ដាម (២:១៦-១៧) ត្រូវបានសំរេច។ នៅពេលដែលពួកគេបានធ្លាក់ចុះភ្លាម ព្រះបានប្រទានផ្លូវនៃសេចក្តីសង្គ្រោះដល់ពួកគេ តាមរយៈ ពូជរបស់ស្ត្រី ព្រះយេស៊ូវគ្រិស្ទ នៅក្នុងសេចក្តីសន្យានៃការអះអាងដោយឯករាជ្យរបស់ព្រះ។ ក្រោយមកសាវ័កប៉ូលបានយល់ពីសេចក្តីពិត យ៉ាងអស្ចារ្យនេះ ហើយបានអះអាងថាព្រះទ្រង់នឹងបំផ្លាញសាតាំងនៅក្រោមជើងរបស់ ពួកបរិសុទ្ធ (រ៉ូម ១៦:២០)។

1. ប្រភេទនៃសេចក្តីសង្គ្រោះ (លោកុប្បត្តិ ៣:២០-២៤)

ការបើកសំដែងនៃការស្តារឡើងវិញនៃរូបធ្លុះរបស់ព្រះចេញមកដំបូងបែបនេះ "ប្រភេទ" ឬ "ស្រមោល" នៃការ សង្គ្រោះនៅក្នុងភាពលំអិត។ ព្រះបន្ទូលមានបន្ទូលថា "នោះព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់ក៏ធ្វើអាវពីស្បែក ឱ្យអ័ដាម និងប្រពន្ធគាត់ពាក់បិទបាំងកាយ" (២១)។ ពាក្យនេះបានសំដៅទៅ ដល់ការសុគតរបស់ព្រះគ្រិស្ទ (Jonathan Edwards) ដោយសារតែលទ្ធផលនៃសំលៀកបំពាក់ស្បែក ត្រូវចេញមកពីការស្លាប់របស់សត្វ។ ហើយការគ្របបាំង របស់សំលៀកបំពាក់នោះគឺជាការគ្របបាំងសេចក្តីគួខ្មាស់ របស់ពួកគេ។ មានតែការសុគត របស់ព្រះអម្ចាស់ព្រះយេស៊ូវ គ្រិស្ទប៉ុណ្ណោះទើបអាចគ្របបាំងសេចក្តីអាម៉ាស នៃអំពើបាបរបស់យើងបាន។ ហេតុនោះ អ្នកណាដែលនៅក្នុងព្រះ គ្រិស្ទយេស៊ូវ នោះគ្មានទោសសោះ (រ៉ូម ៨:១)។ មានន័យថាយើង ត្រូវបានអត់ទោស ឱ្យដោយសារសេចក្តីសប្បុរស របស់ទ្រង់ (ហេព្រើរ ១០:១៧)។ យើងទទួលបានសេចក្តីសង្គ្រោះមិនមែនដោយសារស្រមោលនោះទេ ប៉ុន្តែដោយភាពនៃសេចក្តីសង្គ្រោះ ជាព្រះគ្រិស្ទ។ មានតែការសុគតរបស់ ព្រះយេស៊ូវទេ ដែលអាចដកយើងចេញពីសេចក្តីស្រឡាញ់ មកកាន់ជីវិតបាននាំយើងចេញពីអំណាចរបស់សាតាំង ទៅកាន់ អំណាចចេស្តារបស់ព្រះដោយគ្មានការកាត់ទោស ឡើយ។

នៅទីនេះជាសញ្ញានៃការសង្គ្រោះដែលបានបើកសំដែងម្តងទៀត។ ព្រះបានធ្វើការសន្យាអំពីសេចក្តី សង្គ្រោះ ប៉ុន្តែបាន ធ្វើទៅតាមគោលនៃសេចក្តីសង្គ្រោះ។ ទីមួយព្រះបានហាមពួកគេពីដើមឈើជីវិត (២២)។ ព្រះបានកំណត់ព្រំដែននៃ ការរីករាយដាលរបស់អំពើបាបយ៉ាងរហ័សរហូតដល់ព្រះគ្រិស្ទ ដើមឈើជីវិតបាន មកដល់ ផែនដី។ ទីពីរ ព្រះបានដេញ ពួកគេចេញពីសួនច្បារអេដែន (២៣)។ ដោយសារការកាត់ទោសដល់ មនុស្ស ដែលបានបំផ្លាញការប្រកបគ្នារបស់ ពួកគេ ព្រះត្រង់បានធ្វើឱ្យគេយល់អំពីអំពើបាបដ៏អាក្រក់របស់គេ និង ពះគុណនៃសេចក្តីសង្គ្រោះ។ ដៃយាសារការ អនុញ្ញាតអោយមានសំណាង់នៃវប្បធម៌ ព្រះទ្រង់បានធ្វើឱ្យពួកគេរៀន អំពីសិរីភាពដ៏ពិត ការបែរត្រឡប់ទៅរកព្រះជា ម្ចាស់។ ទីបី ព្រះបានបង្គាប់ឱ្យទេវយាមផ្លូវទៅកាន់សួនច្បារ អេដែន។ មានន័យថាមនុស្សមានបាបមិនអាចចូលទៅសួន ច្បារបានឡើយ (២៤)។ ហើយបានប្រាប់យើង ថាមានតែឈាម របស់ព្រះយេស៊ូវគ្រិស្ទប៉ុណ្ណោះទើបអនុញ្ញាត្តាឱ្យយើង ទៅក្បែរបល្លង្កបាន (ហេព្រើ

រ ១០:១១-១៨)។ យើងគួរតែ ទុកចិត្តលើព្រះគ្រិស្ទ និង ឈើឆ្កាងរបស់ទ្រង់។

## សរុបសេចក្តី:

អ្នកដែលបានបាត់បង់រូបឆ្លុះរបស់ព្រះ អាចមានផ្លូវនៃការស្តារឡើងវិញតាមរយៈព្រះគ្រិស្ទ ដែលជាពូជរបស់ស្ត្រី។ ទោះបីជាគេបាត់បង់សិរីល្អរបស់សួនច្បារអេដែនក៏ដោយ ដែលជាទីដែលគេបានពេញដោយព្រះវត្តមានរបស់ព្រះ គេនូវតែអាចទៅកាន់ព្រះតាមរយៈព្រះគ្រិស្ទ។ ម៉ូសេបានមើលទៅសិរីល្អនៃសេចក្តីសង្រ្គោះ និង ព្រះគុណ នៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះការបើកសំដែងនៃការការបង្កបង្កើតសារជាថ្មី ហើយបានសរសេរសៀវភៅទាំង ប្រាំកណ្ឌឡើង។ ទោះបីជាសាវ័កប៉ូលបានឃើញព្រះភ័ក្ររបស់ទ្រង់នៅ ក្នុងសេចក្តីសង្គ្រោះ ដែលត្រូវបានសំរេច បំពេញដោយបុត្រារបស់ព្រះ ដែលត្រូវបានធ្វើឱ្យស្ញើចសរសើរនៅក្នុងការ ផ្លាស់ប្រែនៃរូបឆ្លុះរបស់ព្រះ (២ កូរិនថូស ៣:១៨)។ ប៉ុន្តែខុសពីការផ្លាស់ប្រែដែលលោកម៉ូសេមាន ដែលគ្រប់ដោយកន្សែងដៃ ប៉ុន្តែវាត្រូវបានផ្លាស់ប្រែទើបយើង អាចមើលឃើញព្រះភក្រ័របស់ព្រះដោយផ្ទាល់បាន។

[សំនួរទី៣] ចូរអានមេរៀនទីបីម្តងទៀត ហើយចូរឱ្យចំលើយដែលសមស្របទៅនឹងសំនួរដូចតទៅនេះ:

1. តើនរណាដែលសំរាកនៅក្នុងព្រះគម្ពីរលោកុប្បត្តហើយអ្វីទៅជាគោលបំណង?-ជាថ្ងៃដែលជាព្រះទ្រង់ផ្ទាល់ បាន ឈប់សំរាក។ព្រះបានទាមទារឱ្យមនុស្សបានឈប់សំរាកដោយរក្សាថ្ងៃសប្ប័ទរបស់ព្រះ ដោយចងចាំ ព្រះដ៏ជាព្រះ អាទិករ ហើយឱ្យមានអំណរនៅក្នុងការសំរាករបស់ព្រះដោយការសញ្ជឹងគិតព្រះបន្ទូលរបស់ ទ្រង់។

2. តើអ្វីទៅជាគោលបំណងដែលព្រះបង្កើតសួនច្បារអេដែន? — ថ្ងៃសប្ប័ទជាថ្ងៃនៃព្រះពរ ហើយសួនច្បារអេ ដែនជាទីកន្លែងនៃព្រះពរ។ ព្រះបានអញ្ជើញមនុស្សឱ្យចូលទៅដើម្បីនឹងមានការប្រកបគ្នា ជាមួយទ្រង់ នៅក្នុងសេចក្តី ស្រលាញ់របស់ព្រះ។

3. ចូរអាន លោកុប្បត្តិ ៣:១-៧ ហើយអនុវត្តគោលការណ៍ ពបសឧប:

១) ព្រះ (១,៣)ទ្រង់បានសូមឱ្យមានការស្តាប់បង្គាប់ទៅព្រះបន្ទូលរបស់ទ្រង់ដោយស្ម័គ្រពីចិត្ត។ —ទោះអ័ដាមស្គាល់ព្រះបន្ទូលរបស់ព្រះ គេនៅតែត្រូវការការស្តាប់បង្គាប់វិជ្ជមានដែរ។

=តើខ្ញុំជាមនុស្សដែលមានចំនេះដឹងឬជាមនុស្សដែលស្តាប់បង្គាប់? ព្រះទ្រង់កំពុងតែរង់ចាំពេលដែលយើងស្តាប់ ព្រះបន្ទូលរបស់ទ្រង់ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ដោយសេចក្តីជំនឿដោយគ្មានលក្ខខណ្ឌ។ នេះជាគោល បំណង នៅក្នុងគំនិតរបស់ខ្ញុំ។

២)បាប - (១ , ៤ និង ៦)ការល្បួងលួងដែលពេញដោយឧបាយកលរបស់សាតាំង-សាតាំងបានធ្វើឱ្យពួកគេ បាន បំបែកបំបាក់ការប្រកបរបស់គេជាមួយនឹងព្រះដោយខ្លួនរបស់ពួកគេដោយជ្រើសរើសយកផ្លែឈើដែល បានហាម ឃាត់។

=ទោះខ្ញុំទទួលយកអំណាចចេស្តានៃព្រះបន្ទូលនៅក្នុងជីវិតពិតរបស់ខ្ញុំក៏ដោយ ខ្ញុំតែងតែអះអាងនូវបំណង របស់ ខ្ញុំជាជាងបំណងព្រះហឫទ័យរបស់ព្រះ។ មានន័យថាខ្ញុំបានធ្លាក់ចុះទៅក្នុងការល្បួងរបស់សាតាំង។ ខ្ញុំត្រូវតែ ស្រឡាញ់ព្រះបន្ទូលរបស់ព្រះ ដើម្បីកុំឱ្យត្រូវធ្លាក់ក្នុងសេចក្តីល្បួងរបស់សាតាំង។

(៦) អេវ៉ាត្រូវបានដឹកនាំដោយសេចក្តីល្បួងរបស់សាតាំង ហើយបានបេះផ្លែឈើដែលបានហាមមិន ឱ្យបរិភោគ ហើយក៏យកទៅប្តីផងដែរ។ ការធ្វើអ្វីដោយចិត្តរបស់ខ្លួនឯងជាដើមចមនៃអំពើរបាប។

=តើចិត្តចង់បានរបស់ខ្ញុំចេញមកពីណា?នៅក្នុងព្រះ ឬ នៅក្នុងខ្ញុំ?របស់ខាងសាច់ឈាម

មានន័យថាការបំពេញ ដោយសេចក្តីត្រេកត្រអាលរបស់ខ្ញុំ។

៣) សន្យា-

៤)ឧទាហរណ៍-

៥)បង្គាប់-

## មេរៀនទី ៤ គោលគំនិតនៃការបើកសំដែងលក្ខណៈជារូបភាព-ការថ្វាយបង្គំដ៏ពិត

១. អាសនានៅចំកណ្តាលរូបភាព - ការថ្វាយបង្គំដ៏ពិតគឺជារឿងដំបូងដែលលោកអ័ដាម នៅពេលដែលត្រូវបានបណ្តេញចេញពីសួនច្បារអេដែន បានរៀន។
២. សត្វដែលពេញដោយឈាមដាក់លើអាសនា - យើងអាចជួបជាមួយនឹងព្រះដោយពឹងផ្អែកលើការសុគតរបស់ព្រះគ្រីស្ទ។
៣. ត្រៃ ប្រាសាទ នឹងរូបភាពនៃការកសាងដែលបានសាងសង់ផ្ទះ - ព្រះបានដកយកព្រះគុណទូទៅ (common grace) ចេញពីលោកកាអីនដែលបរាជ័យក្នុងការថ្វាយបង្គំព្រះជាម្ចាស់។
៤. រូបភាពផ្ទុយគ្នាពីរ - ព្រះបានធ្វើអោយពង្សាវតារបស់លោកកាអីនសំលឹងយកវប្បធម៌ជាធំ តែឯពង្សាវតារបស់លោកអេបិលវិញសំលឹងយកការថ្វាយបង្គំព្រះក្នុងសេចក្តីកោតខ្លាចចំពោះព្រះជាម្ចាស់។
៥. មនុស្សដំបូងដែលត្រូវបានប្រោសនៅក្រោមពន្លឺនៃសត្វព្រាប - ការរស់រៀនដំបូងដែលបានកើតឡើងនៅជំនាន់លោកអេណុស។
៦. រូបភាពនៃការថ្វាយបង្គំរបស់ក្រុមគ្រួសារមួយដែលមានមនុស្សពីរនាក់ឈរនៅកណ្តាល - លោកអេណុកបានភ្លក់នូវការរស់រៀនជាលើទីពីរដែលវាប្រៀបដូចជាផលផ្លែនៃចំរូតរបស់ការរស់រៀនជាថ្មី។

## មេរៀនទី ៤ ការថ្វាយបង្គំដ៏ពិត

I. អត្ថបទ: លោកុប្បត្តិ ៤: ១- ៥: ៣២
II. ខគន្លឹះ លោកុប្បត្តិ ៤: ៣- ៤
III. ការសិក្សាត្រួសៗ

